ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

**អបអរសាទរទិវាជាតិអំណាន លើកទី៩**
**១១ មីនា ២០២៤**

# សិក្ខាកថាក្រោមប្រធានបទ
# "តួនាទីព្រះពុទ្ធសាសនាក្នុងការលើកកម្ពស់ការអប់រំសីលធម៌ និងចរិយាធម៌"

ដោយ យាន សំណាង

ព.ស.២៥៦៧ គ.ស.២០២៤

# ប្រវត្តិរូបសង្ខេបបេក្ខជន

## ព័ត៌មានទូទៅ

- ឈ្មោះ : យាន សំណាង
- ភេទ : ប្រុស
- ថ្ងៃ ខែ ឆ្នាំកំណើត : ០៨ មករា ១៩៩០
- ទីកន្លែងកំណើត : ភូមិបឹងព្រៃង ឃុំសោប ស្រុកព្រែកប្រសព្វ ខេត្តក្រចេះ
- ទីលំនៅបច្ចុប្បន្ន : ភូមិកំពង់ដ ឃុំជ្រោយបន្ទាយ ស្រុកព្រែកប្រសព្វ ខេត្តក្រចេះ
- មុខរបរ : ព្រះសង្ឃ

## ការសិក្សា

- ២០១៦ - ២០១៧ : បញ្ចប់បរិញ្ញាបត្រផ្នែក អក្សរសាស្ត្រខ្មែរ
  នៅសាកលវិទ្យាល័យគ្រប់គ្រងនិងសេដ្ឋកិច្ច ( UME ) ខេត្តក្រចេះ
- ២០១៤ - ២០១៥ : បញ្ចប់បរិញ្ញាបត្រផ្នែក ភាសាអង់គ្លេសសម្រាប់អប់រំ
  នៅសាកលវិទ្យាល័យគ្រប់គ្រងនិងសេដ្ឋកិច្ច ( UME ) ខេត្តបាត់ដំបង
- ២០១០ - ២០១១ : បញ្ចប់វិញ្ញាបនបត្រធម្មមសិក្សាទុតិយភូមិ

## អត្តភាពការងារ

- ២០១៩ - បច្ចុប្បន្ន : បង្រៀនតែងសេចក្តី និងអក្សរសិល្ប៍តាមយូធូប និងផេក Khmer Writing
- ២០១៦ - បច្ចុប្បន្ន : ជានាយក និងជាគ្រូបង្រៀនភាសាអង់គ្លេស
  នៅមជ្ឈមណ្ឌលធនធានថ្មី ខេត្តក្រចេះ
- ២០១៥ - បច្ចុប្បន្ន : ជាចៅអធិការវត្តចន្ទរង្សី-កែង ភូមិកំពង់ដ ឃុំជ្រោយបន្ទាយ ស្រុកព្រែកប្រសព្វ
  ខេត្តក្រចេះ

## ទំនាក់ទំនងបេក្ខជន


- ទូរសព្ទលេខ : ០៩៦ ៩៩ ៣៤៣ ៩៦ / ០៩៧ ៩៩ ៣៤៣ ៩៦
- តេឡេក្រាម : 0979934396 ( @Khmerwriting )
- អ៊ីម៉ែល : yeansamnang@gmail.com

# មាតិកា


I. សេចក្តីផ្តើម ..... 1
II. តួសេចក្តី ..... 1
១- ពន្យល់ពាក្យ ..... 1
ក-ព្រះពុទ្ធសាសនា ..... 1
ខ-តួនាទី ..... 2
គ-សីលធម៌ ..... 2
ឃ-ចរិយាធម៌ ..... 2
២- ពន្យល់ប្រធាន ..... 2
៣- បកស្រាយប្រធាន ..... 3
៣.១- តើព្រះពុទ្ធសាសនាមានតួនាទីអ្វីខ្លះ ? ..... 3
ក-វត្តអារាម ..... 3
ខ-ព្រះសង្ឃ ..... 4
គ-ព្រះពុទ្ធសាសនា និងប្រជាជន ..... 4
ឃ-ព្រះពុទ្ធសាសនា និងប្រទេសជាតិ ..... 4
៣.១- តើព្រះពុទ្ធសាសនាបានបង្រៀនអំពីអ្វីខ្លះ ? ..... 5
ក-សព្វបាបស្ស អករណំ ការមិនធ្វើបាបទាំងពួង ..... 5
ខ-កុសលស្ស ឧបសម្បទា ការញុំាងកុសលឱ្យកើតឡើង ..... 7
គ-សចិត្តបរិយោទបនំ ការញុំាងចិត្តរបស់ខ្លួនឱ្យផូរផង់ ..... 9
៣.២- តើព្រះពុទ្ធសាសនាអប់រំមនុស្សដោយមធ្យោបាយអ្វីខ្លះ ? ..... 10
ក-តាមរយៈការសិក្សាតាមគម្ពីរគោលរបស់ព្រះពុទ្ធសាសនា ..... 10
ខ-តាមរយៈការសម្តែងធម្មទេសនាតាមបុណ្យនានា ..... 10
គ-តាមរយៈការធ្វើបុណ្យបែបព្រះពុទ្ធសាសនាសុទ្ធ ..... 10
ឃ-តាមរយៈការសហការបង្រៀនរបស់ព្រះសង្ឃជាមួយគ្រឹះស្ថានអប់រំនានា ..... 10
ង-តាមរយៈប្រព័ន្ធផ្សព្វផ្សាយ ឬបណ្តាញសង្គមនានា ..... 11
ច-តាមរយៈការលើកស្លាក ឬបដាផ្សេងៗ ..... 11
ឆ-តាមរយៈអក្សរសិល្ប៍ ..... 11
៣.៣- តើព្រះពុទ្ធសាសនាលើកកម្ពស់ការអប់រំសីលធម៌ និងចរិយាធម៌ដូចម្តេចខ្លះ ? ..... 12
ក-សីលធម៌ ..... 12
ខ-ចរិយាធម៌ ..... 17
៤- សរុបសេចក្តី ..... 20
III. សេចក្តីបញ្ចប់ ..... 20
ឯកសារពិគ្រោះ .....

## ប្រធានបទ
## “តួនាទីព្រះពុទ្ធសាសនាក្នុងការលើកកម្ពស់ការអប់រំសីលធម៌ និងចរិយាធម៌”

### I. សេចក្តីផ្តើម

ព្រះពុទ្ធសាសនា ត្រូវបានផ្សាយចូលមកកាន់មណ្ឌលសុវណ្ណភូមិតាំងពីពុទ្ធសតវត្សទី៣ ពោលគឺនៅពុទ្ធសករាជ២៣៤ មុនគ្រឹស្តសករាជ៣០៩ឆ្នាំ។ ក្នុងប្រទេសកម្ពុជាយើង ត្រូវបានគេដឹងថា ព្រះរាជាដែលជ្រះថ្លាទទួលយកព្រះពុទ្ធសាសនាមកគោរពប្រតិបត្តិមុនគេ ឬហៅថាបឋមវង្ស គឺព្រះបាទស្រីមារៈ នៅសតវត្សទី២នៃគ្រឹស្តសករាជ។ ក្រោយមកទៀត ព្រះពុទ្ធសាសនាបានរីកចម្រើនដល់កំពូលក្នុងរជ្ជកាលព្រះបាទជ័យវរ្ម័នទី៧ ដែលព្រះអង្គមានព្រះរាជបុត្រមួយព្រះអង្គព្រះនាម តាមលិន្ទៈ បានចូលបួសក្នុងព្រះពុទ្ធសាសនា ហើយទៅរៀនសូត្រនៅស្រីលង្កាទៀតផង។ ជ្បិតតែ ក្នុងសម័យកាលខ្លះ ប្រទេសជាតិ និងប្រជាជនខ្មែរជួបនូវក្តីទុក្ខលំបាកវេទនាអាប់ឱនក៏ពិតមែន តែព្រះពុទ្ធសាសនាបានចាក់ជ្រៅក្នុងបេះដូងរបស់ប្រជាជនខ្មែរទៅហើយ។ ឱវាទរបស់ព្រះពុទ្ធមិនបានសាបសូន្យពីក្នុងសង្គមខ្មែរឡើយ តែផ្ទុយទៅវិញ ត្រូវបានព្រះរាជា សព្វមុខមន្ត្រី និងប្រជារាស្ត្របានគោរពប្រតិបត្តិជាប់ជានិច្ចរហូតមកដល់សព្វថ្ងៃនេះ។ ដោយសារប្រជាជនខ្មែរភាគច្រើនបំផុត ជាអ្នកកាន់ព្រះពុទ្ធសាសនានេះហើយ ទើបច្បាប់រដ្ឋធម្មនុញ្ញត្រង់មាត្រា៤៣ បានចែងថាព្រះពុទ្ធសាសនាជាសាសនារបស់រដ្ឋ។ នៅគ្រប់សម័យកាល ព្រះពុទ្ធសាសនាបានចូលរួមអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរបស់ប្រទេសជាតិឱ្យមានការរីកចម្រើន និងការអប់រំប្រជាជនខ្មែរឱ្យរស់នៅប្រកបដោយសេចក្តីល្អ និងភាពថ្លៃថ្នូរ។ មកដល់បច្ចុប្បន្ននេះ វិទ្យាសាស្ត្រកាន់តែរីកចម្រើន ដែលធ្វើឱ្យមនុស្សរស់នៅជាមួយនឹងរបស់ប្រើប្រាស់កាន់តែទំនើប។ ក្នុងបរិបទសង្គមដែលកំពុងតែមានការរីកចម្រើនស្ទើរតែគ្រប់វិស័យនេះ ព្រះពុទ្ធសាសនាកាន់តែមានតួនាទីយ៉ាងសំខាន់ក្នុងការអប់រំមនុស្សឱ្យរស់ប្រកបដោយសីលធម៌ និងអប់រំមនុស្សឱ្យប្រព្រឹត្តល្អ ដើម្បីជាប្រយោជន៍សុខសុភមង្គលដល់ខ្លួន ដល់ប្រជាជនកម្ពុជា និងនាំសេចក្តីចម្រើនដល់ប្រទេសជាតិផងដែរ។ ដើម្បីឱ្យមើលឃើញតួនាទីព្រះពុទ្ធសាសនាក្នុងការអប់រំមនុស្សឱ្យកាន់តែច្បាស់ ទើបក្រសួងអប់រំ យុវជន និងកីឡា ក្នុងឱកាសទិវាជាតិអំណានលើកទី៩ បានឱ្យបកស្រាយប្រធានបទមួយស្តីអំពី “តួនាទីព្រះពុទ្ធសាសនាក្នុងការលើកកម្ពស់ការអប់រំសីលធម៌ និងចរិយាធម៌។

តើព្រះពុទ្ធសាសនាមានតួនាទីយ៉ាងណាខ្លះក្នុងការលើកកម្ពស់ការអប់រំសីលធម៌ និងចរិយាធម៌?

### II. តួសេចក្តី

ដើម្បីឱ្យការបកស្រាយនូវប្រធានបទនេះឱ្យមានលក្ខណៈងាយស្រួលស្តាប់ និងងាយស្រួលយល់នោះ ជាដំបូងយើងគប្បីយល់នូវអត្ថន័យនៃពាក្យគន្លឹះ និងឃ្លាគន្លឹះមួយចំនួនជាមុនសិន។

#### ១- ពន្យល់ពាក្យ

#### ក-ព្រះពុទ្ធសាសនា

ព្រះពុទ្ធសាសនា មកពីពាក្យថា “ព្រះពុទ្ធ” ផ្សំនឹងពាក្យថា “សាសនា”។ ក្នុងវចនានុក្រមខ្មែររបស់សម្តេចព្រះសង្ឃរាជ ជួន ណាត បានពន្យល់ថា “ពុទ្ធ” សំដៅដល់លោកអ្នកត្រាស់ដឹងធម៌ដែលកំបាំង ដូចយ៉ាងអរិយសច្ច៤ជាដើម រហូតដល់មគ្គផលនិព្វាន ឬលោកអ្នកភ្ញាក់រឭក គឺមានសតិសម្បជញ្ញៈសព្វកាល ឬ

លោកអ្នករីកពេញទីដូចជាផ្កាឈូកដែលរីកគ្រប់ស្រទាប់ គឺមានព្រះហឫទ័យរីកដោយអំណាចនៃបរិសុទ្ធិ ព្រោះកម្ចាត់កិលេសអស់ហើយ។ ចំណែកពាក្យថា "សាសនា" ក្នុងវចនានុក្រមខ្មែរបានសរសេរថា "សាសនា" ជាពាក្យប្រើក្លាយមកពីពាក្យថា "សាសនៈ" ដែលមានន័យថា "ពាក្យបណ្ដាំ ពាក្យផ្ដាំផ្ញើ ពាក្យប្រៀនប្រដៅ ការប្រៀនប្រដៅ សាសនា លទ្ធិ ពាក្យបង្គាប់ ការបង្គាប់បញ្ជា ដំណឹង សំបុត្រ ពាក្យប្រកាស ការប្រកាសប្រាប់ ការជឿស្ដាប់ ការដាក់ទណ្ឌកម្ម ការផ្ចាលទោស ការកែសម្រួល ការគ្រប់គ្រង ការត្រួតត្រា"។ ក្នុងសៀវភៅ "សាសនាគឺអ្វី?" របស់លោក ម៉ិញ ន៉ាគ្រី បានពន្យល់ថា "ពាក្យទូន្មានប្រៀនប្រដៅរបស់សាស្ដាចារ្យណាមួយក្នុងលោក ហៅថាសាសនា"។ រីឯសៀវភៅ "ប្រស្នាពុទ្ធសាសនា" របស់ព្រះគ្រូសង្ឃសុមេធ ធន់ វ៉ាន់ បានពន្យល់ពាក្យ "សាសនា" ថា "លទ្ធិ ឬបញ្ញត្តិ ឬពាក្យប្រៀនប្រដៅដែលសាស្ដាចារ្យចងក្រងទុកជាភាសិត ឬជាច្បាប់ វិន័យដែលទាក់ទងដោយសីលធម៌ សម្រាប់ប្រដៅមហាជនឱ្យដឹងច្បាស់ថា របស់ណាគួរប្រព្រឹត្ដិ របស់ណាគួរវៀរចាកទាំងផ្លូវកាយ ផ្លូវវាចា និងផ្លូវចិត្ត"។ ជារួមមក ក្នុងវចនានុក្រមខ្មែរបានពន្យល់ថា "ព្រះពុទ្ធសាសនា គឺជាពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធ ពុទ្ធបណ្ដាំ"។ ក្នុងសៀវភៅ "សាសនាគឺអ្វី? បានបញ្ជាក់ន័យឱ្យកាន់តែច្បាស់ថា "ពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធជាអគ្គបុគ្គល ជាសាស្ដាឯកក្នុងលោក ហៅថា ពុទ្ធសាសនា ឬហៅថាពុទ្ធោវាទក៏បាន ហៅថាពុទ្ធវចនៈក៏បាន"។

**ខ-តួនាទី**

តាមវចនានុក្រមខ្មែរបានពន្យល់ថា "តួនាទី" សំដៅដល់ "ភារកិច្ចដែលត្រូវធ្វើតាមមុខងាររបស់ខ្លួន។ ឧទាហរណ៍ តួនាទីរបស់យុវជនក្នុងសង្គមជាតិ"។

**គ-សីលធម៌**

ក្នុងវចនានុក្រមខ្មែរបានពន្យល់ពាក្យ "សីលធម៌" នេះថា "សីលដែលជាធម៌របស់សត្វលោក ឬសីល និងធម៌ កិរិយាមារយាទសណ្ដាប់ធ្នាប់ ដំបូន្មានដែលនាំឱ្យចៀសវាងអំពើអាក្រក់ ហើយឱ្យប្រព្រឹត្តតែអំពើល្អ"។ ម្យ៉ាងទៀតមានន័យថា "គោលការណ៍ និងជំនឿអំពីអាកប្បកិរិយាដែលត្រូវនិងខុស អាកប្បកិរិយាស្ដង់ដា"។ សៀវភៅសិក្សាសង្គម ថ្នាក់ទី១០ របស់ក្រសួងអប់រំយុវជន និងកីឡា បានឱ្យនិយមន័យថា "សីលធម៌ សម្គាល់នូវទ្រឹស្ដីទាំងឡាយណា ដែលនាំឱ្យមនុស្សប្រព្រឹត្តតែអំពើល្អ ឬដំបូន្មានទាំងឡាយណា ដែលនាំឱ្យចៀសវាងអំពើអាក្រក់"។

**ឃ-ចរិយាធម៌**

តាមវចនានុក្រមខ្មែរបានពន្យល់ថា "ចរិយា" មានន័យថាការប្រព្រឹត្ត សំណាង ព្រេង ព្រេងសំណាង។ រីឯពាក្យថា "ធម៌" សំដៅដល់ដំបូន្មាន ធាតុ ទ្រឹស្ដី ឬសភាវៈទ្រទ្រង់។ ជារួមមក ពាក្យថា "ចរិយាធម៌" មានន័យថា ការប្រព្រឹត្តត្រឹមត្រូវខាងផ្លូវកាយ វាចា និងចិត្ត។ ក្នុងគេហទំព័រវចនានុក្រមអង់គ្លេសមួយបានពន្យល់ថា ចរិយាធម៌គឺជាមែកធាងរបស់សីលធម៌។ ដូចនេះ យើងអាចនិយាយបានថា ចរិយាធម៌ គឺសង្កត់ធ្ងន់ទៅលើការប្រតិបត្តិតាមគោលសីលធម៌ទាំងឡាយណាដែលស្របទៅនឹងច្បាប់ សិក្ខាបទ ឬក្រឹត្យវិន័យជាដើម ដែលនាំទៅរកសេចក្ដីចម្រើន។

**២- ពន្យល់ប្រធាន**

បើពិនិត្យទៅលើអត្ថន័យនៃពាក្យគន្លឹះ និងឃ្លាគន្លឹះ យើងឃើញថា ប្រធានបទនេះ ចង់ឱ្យធ្វើការបកស្រាយអំពីភារកិច្ចរបស់ព្រះពុទ្ធសាសនា ក្នុងការយកនូវក្បួនច្បាប់ ធម៌វិន័យ ឬគោលគំនិតមកអប់រំទូន្មាន

ប្រៀនប្រដៅ ឬបណ្តុះគំនិតដើម្បីលើកតម្កើងតម្លៃនៃអំពើល្អរបស់មនុស្សនៅក្នុងសង្គម។ ការបកស្រាយពន្យល់នោះ គឺត្រូវបង្ហាញឱ្យឃើញអំពី តួនាទីរបស់ព្រះពុទ្ធសាសនាក្នុងការចូលរួមអប់រំមនុស្ស និងជួយសង្គម គោលគំនិតសំខាន់ៗរបស់ព្រះពុទ្ធសាសនា មធ្យោបាយនៃការអប់រំទូន្មាន និងលទ្ធផលដែលកើតចេញពីការអប់រំតាមបែបព្រះពុទ្ធសាសនា។

**៣- បកស្រាយប្រធាន**

ជាការពិតណាស់ ព្រះពុទ្ធសាសនាពិតជាមានតួនាទីយ៉ាងសំខាន់ក្នុងការលើកកម្ពស់សីលធម៌ និងចរិយាធម៌។ យើងឃើញថា តាំងពីបុរាណកាលមក ព្រះពុទ្ធសាសនាបានចូលរួមចំណែកយ៉ាងច្រើនក្នុងការជួយប្រទេសកម្ពុជាទាំងការកសាងជាតិ និងការកសាងធនធានមនុស្ស។ បើយើងនិយាយឱ្យកាន់តែទូលាយ ព្រះពុទ្ធសាសនាមិនត្រឹមតែសំដៅយកនូវពាក្យទូន្មានប្រៀនប្រដៅរបស់ព្រះសម្មាសម្ពុទ្ធនោះទេ តែក៏រាប់បញ្ចូលទាំងវត្តអារាម និងព្រះសង្ឃ ដែលជាធាតុរួមផ្សំមិនអាចខ្វះបានរបស់ព្រះពុទ្ធសាសនា។ ទាំងមេរៀនរបស់ព្រះពុទ្ធ ទាំងធាតុផ្សំរបស់ព្រះពុទ្ធសាសនា គឺសុទ្ធតែមានគុណសម្បត្តិច្រើនសម្រាប់ប្រទេសកម្ពុជា។

**៣.១- តើព្រះពុទ្ធសាសនាមានតួនាទីអ្វីខ្លះ?**

**ក-វត្តអារាម**

វត្តអារាមព្រះពុទ្ធសាសនា មិនត្រឹមតែជាកន្លែងស្នាក់នៅរបស់ព្រះសង្ឃដែលជាសាវ័កនៃព្រះពុទ្ធនោះទេ តែវត្តអារាមទាំងនោះមានតួនាទីយ៉ាងច្រើនក្នុងសង្គមខ្មែរផងដែរ។ តាំងពីបុរាណមក វត្តអារាមព្រះពុទ្ធសាសនា ទុកជាគ្រឹះស្ថាន ឬមហាមន្ទីរសម្រាប់ថែរក្សា និងផ្សព្វផ្សាយនូវក្បួនច្បាប់ផ្សេងៗ មានសិល្បៈ ទស្សនវិទ្យា វិទ្យាសាស្ត្រ និងប្រពៃណីទំនៀមទម្លាប់ជាដើម។ បច្ចុប្បន្ននេះ គេនៅតែអាចទទួលបានឯកសារជាច្រើនពីវត្តអារាម។ ម្យ៉ាងវិញទៀត វត្តអារាមគឺជាសាលារៀនសម្រាប់ផ្តល់នូវចំណេះដឹងដល់ព្រះសង្ឃ និងគ្រហស្ថជាច្រើន។ ព្រះសង្ឃ និងគ្រហស្ថទាំងនោះ ខ្លះក៏បានរៀនចេះដឹងដោយផ្ទាល់ចេញពីវត្តអារាម ហើយខ្លះក៏ស្នាក់នៅវត្តដើម្បីបានរៀនសូត្របន្តនៅខាងក្រៅ។ ជាក់ស្តែង កន្លងមកក៏មានថ្នាក់ដឹកនាំប្រទេសមួយចំនួនដែលបានក្លាយជាអ្នកចេះដឹង មានសមត្ថភាពអាចដឹកនាំកសាងប្រទេសជាតិ និងដឹកនាំស្ថាប័នផ្សេងៗបាន គឺដោយសារការរៀនសូត្រតាមរយៈវត្តអារាមនេះឯង។ បន្ថែមពីលើនេះ វត្តអារាមគឺជាមន្ទីរពេទ្យសម្រាប់ព្យាបាលជំងឺផ្លូវចិត្តដ៏មានប្រសិទ្ធភាព។ ប្រជាជនខ្មែរភាគច្រើន ឱ្យតែមានទុក្ខលំបាកផ្សេងៗ ពួកគាត់តែងនឹកឃើញដល់ព្រះសង្ឃ និងនឹកឃើញដល់វត្តអារាមដែលជាកន្លែងគោរពប្រតិបត្តិ និងជាទីពឹងរបស់ពួកគាត់។ ម្យ៉ាងវិញទៀត វត្តអារាមរបស់ព្រះពុទ្ធសាសនា ក៏ជាទីកន្លែងដែលប្រជាជនអាចជួបជុំគ្នាក្នុងការធ្វើអ្វីមួយ ដូចជាការប្រជុំសហគមន៍ ការដោះស្រាយវិវាទផ្សេងៗ ព្រោះថាជាកន្លែងដែលមានទីដីទូលាយ និងងាយស្រួលចំណាំក្នុងការជួបជុំគ្នា។ ហេដ្ឋារចនាសម្ព័ន្ធនានារបស់ព្រះពុទ្ធសាសនា មានដូចជាសាលាឆាន់ កុដិ ព្រះវិហារ របង ខ្លោងទ្វារជាដើម សុទ្ធសឹងតែជាវត្ថុដ៏មានតម្លៃសម្រាប់ជាតិ ព្រោះថាសំណង់នៅតាមវត្តអារាមបានបង្ហាញនូវក្បូរក្បាច់រចនាដែលជាសិល្បៈដ៏ល្អវិចិត្ររបស់ខ្មែរយើង។ របស់ទាំងអស់នោះ មិនត្រឹមតែជាសម្បត្តិតំណាងឱ្យប្រទេសកម្ពុជានោះទេ ថែមទាំងជាមណ្ឌលទេសចរណ៍ និងជាទីកន្លែងដែលមានសោភណភាពបរិស្ថានស្អាត ដែលជួយបង្កើនដល់សេដ្ឋកិច្ចជាតិទៀតផង។ នេះមានន័យថា បើគ្មានព្រះពុទ្ធសាសនា ក៏គ្មានវត្តអារាមដែលជាកន្លែងដ៏មានគុណសម្បត្តិមិនអាចកាត់ថ្លៃបានរបស់ប្រទេសកម្ពុជានេះដែរ។

តួនាទីវត្តអារាមព្រះពុទ្ធសាសនាមានច្រើនដូចបានរៀបរាប់មកនេះ បញ្ជាក់ឱ្យយើងឃើញថា ព្រះពុទ្ធសាសនាពិតជាមានតួនាទីយ៉ាងសំខាន់ក្នុងការជួយជាតិ និងប្រជារាស្ត្រខ្មែរ។ ហេតុនេះហើយ ក្នុងប្រវត្តិសាស្ត្របានបង្ហាញថា រាល់ពេលដែលខ្មែរមានសង្គ្រាមជាមួយប្រទេសដទៃនោះ ពួកបច្ចាមិត្តទាំងនោះតែងដុតបំផ្លាញវត្តអារាម ព្រោះពួកគេដឹងថា វត្តអារាមជាបេះដូង និងជាដួងព្រលឹងរបស់ជាតិខ្មែរ។

**ខ-ព្រះសង្ឃ**

ព្រះសង្ឃ គឺជាសាវ័ករបស់ព្រះពុទ្ធ និងជាអ្នកដែលមានតួនាទីដ៏ចម្បងជាងគេក្នុងការសិក្សារៀនសូត្រ និងទ្រទ្រង់នូវធម៌វិន័យដើម្បីឱ្យព្រះពុទ្ធសាសនាបានគង់វង្សយូរអង្វែង។ ជាងនេះទៅទៀត ព្រះសង្ឃត្រូវដើរតួនាទីយ៉ាងសំខាន់បំផុតក្នុងការផ្សព្វផ្សាយព្រះពុទ្ធវចនៈទៅដល់មនុស្សក្នុងសង្គម។ តាំងពីបុរាណកាលមក ព្រះសង្ឃមានកិត្យានុភាពខ្ពស់ ហើយមានឥទ្ធិពលធំធេងណាស់ទៅក្នុងជីវភាពរស់នៅរបស់ប្រជាជន។ ព្រះសង្ឃតែងមានមេត្តាធម៌ មានចិត្តសន្តោសប្រណីដល់ជនទូទៅ។ ដូច្នេះ ព្រះសង្ឃបានបង្ហាញនូវអាកប្បកិរិយាគំរូខាងផ្នែកសីលធម៌ និងចរិយាធម៌ជាដើមដល់សង្គមខ្មែរទាំងមូល។ បន្ថែមពីលើនេះ ព្រះសង្ឃគឺជាគ្រូបង្រៀនដ៏មានគុណភាព និងធ្វើឱ្យសិស្សមានក្រមសីលធម៌ជាទីបំផុត។ យើងឃើញថា មានកូនខ្មែរជាច្រើនមានចំណេះជំនាញដោយសារការរៀនសូត្រជាមួយព្រះសង្ឃ។ មកដល់បច្ចុប្បន្ន ព្រះសង្ឃមានឱកាសរៀនសូត្របានកាន់តែខ្ពស់ ហើយព្រះអង្គខ្លះបានបើកជាអង្គការ ឬមជ្ឈមណ្ឌលសិក្សាផ្សេងៗដើម្បីជួយបណ្តុះបណ្តាលដល់កូនខ្មែរ។ ព្រះសង្ឃមិនត្រឹមតែចូលរួមជួយប្រជាជនខ្មែរខាងផ្នែកចំណេះដឹងនោះទេ តែក៏ចូលរួមកសាងប្រទេសជាតិផងដែរ។ ជាក់ស្តែង យើងឃើញថាមានសំណង់អគារសិក្សា មន្ទីរពេទ្យ និងហេដ្ឋារចនាសម្ព័ន្ធមួយចំនួនត្រូវបានដឹកនាំកសាងដោយព្រះសង្ឃ ហើយក៏មានដាក់ព្រះនាមរបស់លោកដោយផ្ទាល់ដើម្បីជាសក្ខីភាពទៀតផង។ ដូច្នេះ ព្រះសង្ឃដែលបានបួសរៀនក្នុងសំណាក់ព្រះពុទ្ធសាសនា ពិតជាមានតួនាទី និងគុណសម្បត្តិយ៉ាងច្រើនក្នុងការជួយប្រជាជន និងប្រទេសកម្ពុជា។

**គ-ព្រះពុទ្ធសាសនា និងប្រជាជន**

ព្រះពុទ្ធសាសនា សំដៅដល់ពាក្យទូន្មានប្រៀនប្រដៅរបស់ព្រះពុទ្ធ។ ពុទ្ធវចនៈនេះហើយ ទើបជាតួពិតប្រាកដនៃព្រះពុទ្ធសាសនា។ ទ្រឹស្តីរបស់ព្រះពុទ្ធសាសនា មានសារៈសំខាន់ណាស់សម្រាប់មនុស្សគ្រប់រូប។ ព្រះពុទ្ធសាសនា និងប្រជាជនខ្មែរ គឺមានទំនាក់ទំនងគ្នាយ៉ាងខ្លាំង។ ទោះបីប្រទេសខ្មែរបានជួបនូវវិបត្តិសង្គ្រាមជាច្រើនលើកច្រើនសារ ក៏ប្រជាជនខ្មែរមិនបានបោះបង់ព្រះពុទ្ធសាសនាដែរ។ ខ្មែរយើងជាច្រើនបានសិក្សា និងទទួលយកនូវព្រះពុទ្ធសាសនាដើម្បីគោរពប្រតិបត្តិរហូតមកដល់បច្ចុប្បន្ននេះ។ ទ្រឹស្តីកម្មផលរបស់ព្រះពុទ្ធសាសនាដែលបានលើកឡើងថា "ធ្វើល្អបានល្អ ធ្វើអាក្រក់បានអាក្រក់" គឺបានអប់រំឱ្យពុទ្ធបរិស័ទធ្វើតែអំពើល្អ ហើយអ្នកទាំងនោះក៏បានខិតខំទូន្មានកូនចៅជំនាន់ក្រោយឱ្យធ្វើអំពើល្អថែមទៀតផង។ បន្ថែមពីលើនេះ ព្រះពុទ្ធឱវាទបានធ្វើឱ្យមនុស្សចេះគោរពមាតាបិតា គោរពតួនាទី ចេះសាមគ្គីគ្នា ចេះជួយគ្នា និងចេះធ្វើសេចក្តីល្អជាច្រើនទៀត។ ដូចនេះ ព្រះពុទ្ធវចនៈពិតជាមានតួនាទីសំខាន់ណាស់ក្នុងការអប់រំផ្លូវចិត្តឱ្យប្រជាជនខ្មែរចេះយកខន្តីមកដាក់ខ្លួន ដោះស្រាយបញ្ហាដោយសន្តិវិធី និងការខិតខំកសាងនូវអំពើល្អ។

**ឃ-ព្រះពុទ្ធសាសនា និងប្រទេសជាតិ**

ការគោរពតាមពាក្យប្រៀនប្រដៅរបស់ព្រះសម្មាសម្ពុទ្ធ មិនត្រឹមតែផ្តល់នូវសេចក្តីសុខដល់បុគ្គលអ្នកប្រតិបត្តិនោះទេ ថែមទាំងនាំមកនូវភាពថ្លៃថ្នូរ និងការរីកចម្រើនដល់សង្គមផងដែរ។ ជាទូទៅអ្នកដែលដើរ

តាមការបង្រៀនរបស់ព្រះពុទ្ធតែងតែចេះធ្វើនូវសង្គហធម៌ ឬការចែករំលែកផ្សេងៗ។ ជាក់ស្តែង ការចូលរួមគ្នាធ្វើបុណ្យផ្កាប្រាក់ដើម្បីកសាងវត្តអារាម សាលារៀន ឬមន្ទីរពេទ្យជាដើមនោះ គឺជាចំណែកមួយក្នុងការជួយអភិវឌ្ឍប្រទេសជាតិជាមួយថ្នាក់ដឹកនាំប្រទេស។ ម្យ៉ាងវិញទៀត អំពើល្អទាំងឡាយមានការធ្វើទានជាដើម នឹងធ្វើឱ្យមនុស្សរស់នៅប្រកបដោយការសាមគ្គីគ្នា និងការអនុគ្រោះគ្នា ហើយអំពើល្អទាំងនោះគឺបានផ្សាយនូវគំរូនៃសេចក្តីល្អទៅក្នុងសង្គមទៀតផង។ ព្រះពុទ្ធឱវាទក៏មានតួនាទីធ្វើឱ្យប្រទេសជាតិមានសុខសន្តិភាពផងដែរ ព្រោះថា ព្រះពុទ្ធទ្រង់បង្រៀនអ្នកដឹកនាំ និងប្រជារាស្ត្រឱ្យចេះដោះស្រាយបញ្ហាដោយសន្តិវិធី មិនមែនដោះស្រាយដោយហិង្សាឡើយ។ ការរស់នៅដោយមានមេត្តានោះ នឹងធ្វើឱ្យមនុស្សរាប់អានអ្នកដទៃមកពីគ្រប់ជាតិសាសន៍ដោយមិនមានការរើសអើង។ ការមិនរើសអើងគ្នា និងការគោរពគ្នានេះហើយ គឺជាធាតុសំខាន់មួយក្នុងការធ្វើឱ្យសង្គមមានសន្តិភាព។ ផ្ទុយទៅវិញ អ្នកដែលមិនបានទទួលការអប់រំតាមព្រះពុទ្ធោវាទ ហើយទៅប្រព្រឹត្តអំពើអាក្រក់ មានការលួចឆក់ប្លន់ បង្កអំពើហិង្សាផ្សេងៗជាដើម បានធ្វើឱ្យសង្គមមានអសន្តិសុខ។ ការធ្វើអំពើប្រាសចាកសីលធម៌ទាំងនោះ មិនត្រឹមតែនាំទុក្ខដល់ខ្លួនឯងនោះទេ គឺបានធ្វើឱ្យគ្រោះថ្នាក់ដល់អ្នកដទៃ មានការបាត់បង់អាយុជីវិត ព្រមទាំងធ្វើឱ្យប៉ះពាល់ដល់សេដ្ឋកិច្ចគ្រួសារ និងសេដ្ឋកិច្ចជាតិទៀតផង។ នេះមានន័យថា អ្នកដែលដើរតាមមាគ៌ារបស់ព្រះពុទ្ធសាសនានឹងបានសេចក្តីសុខចម្រើន តែអ្នកដែលដើរប្រាសចាកសីលធម៌ នឹងបង្កទៅជាទុក្ខលំបាកផ្សេងៗ។ ដូច្នេះ ព្រះពុទ្ធសាសនាពិតជាមានតួនាទីយ៉ាងសំខាន់ក្នុងការជួយសង្គមឱ្យមានសុខសន្តិភាព និងការរីកចម្រើនប្រកបដោយភាពថ្លៃថ្នូរ។

### ៣.១- តើព្រះពុទ្ធសាសនាបានបង្រៀនអំពីអ្វីខ្លះ?

ពាក្យទូន្មានរបស់ព្រះពុទ្ធគ្រប់ព្រះអង្គ ទោះបីចែកចេញជាគម្ពីរ ជាវគ្គ ជានិទាន ឬជាមាតិកាធម៌ច្រើនក៏ដោយ គង់ចាត់ចូលក្នុងគោលធម៌៣យ៉ាង ដូចមានពុទ្ធគាថា ថា “សព្វបាបស្ស អករណំ កុសលស្សូ បសម្បទា សចិត្តបរិយោទបនំ ឯតំ ពុទ្ធានសាសនំ” ដែលមានន័យថា “ការមិនធ្វើបាបទាំងពួង១ ការញុំាងកុសលឱ្យកើត១ ការញុំាងចិត្តរបស់ខ្លួនឱ្យផូរផង់១ គោលទាំង៣នេះ គឺជាពាក្យប្រៀនប្រដៅនៃព្រះពុទ្ធទាំងឡាយ”។

**ក-សព្វបាបស្ស អករណំ ការមិនធ្វើបាបទាំងពួង**

ការបង្រៀនដំបូងរបស់ព្រះពុទ្ធសាសនា គឺការប្រៀនប្រដៅមនុស្សមិនឱ្យធ្វើនូវអំពើបាបទាំងពួង។ អំពើបាប យើងអាចហៅថាជាអំពើទុច្ចរិត អំពើអាក្រក់ ឬអំពើអកុសលក៏បាន។ អំពើបាបនោះ សំដៅដល់ការធ្វើអាក្រក់ចំពោះជីវិតមនុស្សសត្វ ចំពោះទ្រព្យសម្បត្តិ និងទីកន្លែងរបស់អ្នកដទៃ។ អំពើអាក្រក់មានច្រើនយ៉ាង ដូចជាការប្រព្រឹត្តនូវវេរកម្ម គឺទង្វើនាំឱ្យមានពៀរផ្សេងៗ និងការធ្វើនូវមិច្ឆាជីវៈ គឺការចិញ្ចឹមជីវិតដោយខុសធម៌ មានការជួញដូរថ្នាំញៀនជាដើម។ ក្នុងទីនេះ យើងនឹងបានសិក្សាជាមួយគ្នាអំពីអកុសលកម្មបថ១០ ដែលជាឧទាហរណ៍មួយបង្ហាញអំពីអំពើអាក្រក់។ អកុសលកម្មបថ មានន័យថា ផ្លូវដែលនាំឱ្យកើតបាប ឬហៅថាទុច្ចរិតកម្មក៏បាន។ អកុសលកម្មបថនោះ ចែកចេញជា កាយទុច្ចរិត៣ វចីទុច្ចរិត៤ និងមនោទុច្ចរិត៣។

កាយទុច្ចរិត គឺការប្រព្រឹត្តអាក្រក់តាមផ្លូវកាយ មានដូចជា ការសម្លាប់សត្វមានជីវិត១ ការលួចទ្រព្យសម្បត្តិអ្នកដទៃ១ និងការប្រព្រឹត្តខុសក្នុងកាមទាំងឡាយ១។ អ្នកដែលប្រព្រឹត្តិបៀតបៀន កាប់សម្លាប់អ្នកដទៃ នឹងធ្វើឱ្យអ្នកដទៃនោះរងទុក្ខលំបាក បង្កទៅជាគំនុំគុំគួន អាចឈានទៅដល់ការសងសឹកគ្នាទៅវិញទៅមក បណ្តាលឱ្យមានបញ្ហាអសន្តិសុខក្នុងសង្គមទៀតផង។ បើគិតអំពីសិទ្ធិសេរីភាពវិញ ការបៀតបៀនគេនេះ

គឺបានធ្វើឱ្យប៉ះពាល់សិទ្ធិនៃការរស់រានមានជីវិតរបស់អ្នកដទៃ។ ចំណែក ការលួចទ្រព្យអ្នកដទៃវិញ សំដៅដល់ការលួច ឆក់ ប្លន់ នូវទ្រព្យសម្បត្តិដែលគេមិនបានឱ្យដោយកាយ ឬដោយវាចា។ អំពើអាក្រក់មួយនេះបានធ្វើឱ្យអ្នកដទៃត្រូវខូចខាតទ្រព្យសម្បត្តិ ឬប៉ះពាល់ដល់រាងកាយ និងអាយុជីវិតក៏ថាបាន។ រីឯការប្រព្រឹត្តខុសក្នុងកាមវិញ សំដៅដល់ការក្បត់ប្ដី ឬក្បត់ប្រពន្ធ ទៅលួចលាក់ទាក់ទងអ្នកដទៃ ឬការរួមមេត្រីជាមួយប្ដីប្រពន្ធអ្នកដទៃ។ នេះជាអំពើអសីលធម៌យ៉ាងខ្លាំង ហើយក៏ធ្វើឱ្យប៉ះពាល់ដល់ច្បាប់ឯកពន្ធភាព ដែលជាច្បាប់និយាយអំពីការស្ម័គ្រចិត្តប្ដីមួយប្រពន្ធមួយផងដែរ។ ការប្រព្រឹត្តល្មើសជាមួយប្ដីប្រពន្ធអ្នកដទៃនេះ ក៏អាចបង្កទៅជាអំពើហិង្សា ការកាប់សម្លាប់គ្នា ធ្វើឱ្យគ្រួសារគេមានវិវាទទាស់ទែងគ្នា និងបាត់បង់សុភមង្គល ព្រមទាំងអាចឈានទៅដល់ការលែងលះគ្នាទៀតផង។

វចីទុច្ចរិត គឺការធ្វើអាក្រក់ដោយពាក្យសម្ដី។ ការធ្វើទុច្ចរិតតាមផ្លូវវាចានេះ មានដូចជា ការពោលពាក្យកុហក១ និយាយញុះញង់បំបែកបំបាក់អ្នកដទៃ១ ការជេរប្រទេចផ្ដាសា១ និងការនិយាពាក្យឡេះឡោះឥតប្រយោជន៍១។ ការនិយាយកុហកនេះ នឹងធ្វើឱ្យមនុស្សបាត់បង់ព័ត៌មានពិត ហើយបែរជាទទួលបានព័ត៌មានប្រតិដ្ឋ ដែលជាហេតុធ្វើឱ្យប៉ះពាល់ដល់ការរស់នៅរបស់ប្រជាជន។ រីឯការនិយាយញុះញង់វិញ នឹងធ្វើឱ្យមានការបែកបាក់សាមគ្គីភាព មិត្តភក្ដិត្រូវខឹងគ្នា គ្រួសារត្រូវបាត់បង់សុភមង្គលជាដើម។ ចំណែក ការប្រើប្រាស់ពាក្យជេរប្រទេចផ្ដាសា នឹងធ្វើឱ្យមនុស្សកើតចិត្តមួរម៉ៅក្ដៅក្រហាយធ្វើអ្វីមិនកើត ហើយអាចបណ្ដាលឱ្យទៅជាមានអំពើហិង្សាទៀតផង។ បន្ថែមពីលើនេះ ការនិយាយពាក្យឡេះឡោះ នឹងធ្វើឱ្យគេបាត់បង់ជំនឿ លែងទុកចិត្ត ព្រមទាំងធ្វើឱ្យខូចខាតពេលវេលាជាដើម។

មនោទុច្ចរិត គឺការធ្វើអាក្រក់តាមផ្លូវចិត្ត។ អំពើអាក្រក់តាមផ្លូវចិត្តនេះមានដូចជា ការគិតរំពៃចង់បានរបស់ទ្រព្យអ្នកដទៃ១ ការគិតចង់ប្រទូស៉ាយអ្នកដទៃឱ្យគេដល់នូវសេចក្ដីវិនាស១ និងការគិតយល់ខុសថាគ្មានបាបបុណ្យគុណទោសជាដើម១។ អំពើបាបតាមផ្លូវចិត្តនេះ នឹងបណ្ដាលឱ្យមានការធ្វើអាក្រក់ដោយកាយ និងដោយវាចាផងដែរ ព្រោះថា កាយនិងវាចា គឺចិត្តជាអ្នកបញ្ជា ដូចមានពុទ្ធភាសិតថា “មនោបុព្វង្គមា ធម្មា មនោសេដ្ឋា មនោមយា មនសា ចេ បទុដ្ឋេន ភាសតិ វា ករោតិ វា តតោ នំ ទុក្ខមន្វេតិ ចក្កំវ វហតោ បទំ។ ធម៌ទាំងឡាយ មានចិត្តជាប្រធាន មានចិត្តប្រសើរបំផុត សម្រេចមកអំពីចិត្ត បើបុគ្គលមានចិត្តត្រូវទោសៈប្រទូស៉ាយហើយ ទោះបីនិយាយក្ដី ធ្វើក្ដី ក៏អាក្រក់ដែរ ព្រោះអំពើអាក្រក់នោះឯង សេចក្ដីទុក្ខរមែងដេញជាប់តាមក្រោយបុគ្គលនោះ ដូចជាកង់រទេះវិលតាមដានជើងគោដែលកំពុងអូសទៅ យ៉ាងដូច្នោះឯង។”

ការប្រព្រឹត្តអាក្រក់ ទាំងបីផ្លូវនេះ ទោះបីក្នុងទីស្ងាត់កំបាំងអំពីអ្នកដទៃក្ដី ឬក្នុងទីចំពោះមុខអ្នកដទៃក្ដី ក៏ឈ្មោះថាបាបទាំងអស់។ ការធ្វើនូវអំពើអាក្រក់នេះ ក៏ជាអំពើខុសទៅនឹងច្បាស់ប្រទេសផងដែរ ដូចជាការកាប់សម្លាប់មនុស្ស ការលួច ឆក់ ប្លន់ជាដើម។ ទង្វើទាំងអស់នេះ គឺជាអំពើប្រាសចាកក្រមសីលធម៌ ដែលធ្វើឱ្យសង្គមមានអសន្តិសុខ និងប៉ះពាល់ដល់ការអភិវឌ្ឍទៀតផង។ បុគ្គលអ្នកធ្វើបាប កាលបើនឹកឃើញនូវអំពើទុច្ចរិតដែលខ្លួនបានធ្វើរមែងតិះដៀលខ្លួនឯង ថាជាមនុស្សប្រព្រឹត្តិអាក្រក់ថោកទាប។ ពេលមរណកាលជិតមកដល់ តែងកើតក្ដៅក្រហាយស្ដាយក្រោយ ដោយមាននិមិត្តអាក្រក់មកបណ្ដាលឱ្យឃើញ នាំឱ្យភ័យញាប់ញ័រក៏មាន ឃើញខ្លួនឯងធ្វើបាបខ្លួនឯងដែលនាំឱ្យមានវិប្បដិសារីក៏មាន។ អ្នកដែលធ្វើអំពើបាបអកុសលរមែងដល់នូវសេចក្ដីទុក្ខទោសដោយមិនអាចគេចផុតឡើយ ដូចពុទ្ធភាសិតថា “ទុក្ខោ បាបស្ស ឧច្ចយោ” ដែលមានន័យថា ការសន្សំនូវបាប ជាហេតុនាំមកនូវសេចក្ដីទុក្ខ។

### ខ-កុសលស្ស បសម្បទា ការញុំាងកុសលឱ្យកើតឡើង

ពាក្យថា "កុសល" សំដៅដល់អំពើល្អ ឬអំពើសុចរិតផ្សេងៗមានការធ្វើទាន និងការរក្សាសីលជាដើម។ ពាក្យថា "ញុំាងកុសលឱ្យកើត" គឺជាពាក្យប្រៀនប្រដៅថ្នាក់កណ្តាល ដែលបុគ្គលត្រូវបំពេញ បន្ទាប់ពីបានលះបង់អំពើអាក្រក់ហើយ។ នេះមានន័យថា មិនមែនលះបង់បាបហើយ ក៏ផ្អាកត្រឹមប៉ុណ្ណោះទេ គឺត្រូវបំពេញករណីយកិច្ចក្នុងការបណ្តុះ ចម្រើនបុណ្យកុសលឱ្យកើតមានឡើងតទៅទៀត។ លោកប្រៀបប្រដូចទៅនឹងដីដែលគេបានរានរើយកមែកឈើ យកសំរាម ឬគល់ឈើចេញអស់ ហើយត្រូវបណ្តុះដំណាំផ្សេងៗមានពោតសណ្តែកជាដើមត្រង់កន្លែងនោះឡើងទៀត។

ការងារជាកុសល ឬវត្ថុសម្រាប់ឱ្យកើតបុណ្យ ហៅថាបុញ្ញកិរិយាវត្ថុ។ បុញ្ញកិរិយាវត្ថុ បើនិយាយដោយសង្ខេបមាន៣យ៉ាង ទាន១ សីល១ ភាវនា១។ បុញ្ញកិរិយាវត្ថុនេះ បើនិយាយឱ្យពិស្តារ មាន១០យ៉ាងគឺ៖

#### ១-ទានមយៈ បុណ្យកើតអំពីការធ្វើទាន

ការធ្វើទាន គឺការលះបង់ ឬការបរិច្ចាគនូវអ្វីៗដែលគួរឱ្យ។ ការឱ្យទាននេះមាន២យ៉ាងគឺ អាមិសទាន១ និងធម្មទាន១។ ការឱ្យវត្ថុប្រើប្រាស់គ្រប់យ៉ាងមានបាយ ទឹក នំ ចំណី វត្ថុប្រើប្រាស់ផ្សេងៗ រាប់ទាំងជីវិតរបស់មនុស្សផង ហៅថា អាមិសទាន។ ការឱ្យអាមិសទាននេះ នឹងធ្វើឱ្យអ្នកទទួលមានកម្លាំង បំបាត់សេចក្តីស្រេកឃ្លាន និងធ្វើឱ្យមានពណ៌សម្បុរល្អជាដើម។ ទន្ទឹមនឹងនោះ អ្នកបានធ្វើទាននឹងមានកេរ្តិ៍ឈ្មោះល្អ មានគេស្រឡាញ់រាប់អានច្រើន។ ការធ្វើទានសម្រាប់ជនទូទៅ គឺជាការអនុគ្រោះដោយល្អសម្រាប់មនុស្សជាតិ ឱ្យគេបានសុខ និងជាការបង្កើតនូវសាមគ្គីភាពផងដែរ។ ចំណែកធម្មទានវិញ សំដៅដល់ការឱ្យធម៌ជាទាន រួមមានការសម្តែងព្រះធម៌ ការផ្តល់ឱវាទ ការបង្រៀន និងការឱ្យជាសៀវភៅធម៌ជាដើម។ ការធ្វើធម្មទាននេះ នឹងបានផ្តល់ជាចំណេះដឹង ព្រមទាំងធ្វើឱ្យមនុស្សស្គាល់ហេតុផល។ ជាឧទាហរណ៍ ព្រះសង្ឃសម្តែងធម៌ទេសនា លោកតែងពន្យល់ឱ្យមនុស្សស្គាល់បាបបុណ្យគុណទោស ដឹងគុណមាតាបិតា និងចេះសន្តោសដល់មនុស្សដទៃ។ រីឯការបង្រៀនសិស្សរបស់លោកគ្រូអ្នកគ្រូវិញ បានធ្វើឱ្យសិស្សមានចំណេះដឹងដែលជាធនធានយ៉ាងមានតម្លៃ សម្រាប់សង្គមជាតិ។ ព្រះពុទ្ធចាត់ទុកធម្មទានថាជាទានដ៏ប្រសើរ ដូចមានពុទ្ធភាសិតថា "សព្វទានំ ធម្មទានំ ជិនាតិ" មានន័យថា ធម្មទានឈ្នះអស់ទានទាំងពួង។ ដ្បិតតែការសម្តែងធម៌ និងការឱ្យនូវចំណេះដឹងមានលក្ខណៈប្រសើរជាងទានដទៃមែន តែព្រះពុទ្ធមិនបានឱ្យយើងបោះបង់នូវការឱ្យទានជាវត្ថុផ្សេងៗមានបាយទឹកជាដើមឡើយ ព្រោះថា មនុស្សយើងមានកម្លាំងហើយទើបអាចស្តាប់ធម៌ និងរៀនសូត្របាន។

#### ២-សីលមយៈ បុណ្យកើតអំពីការរក្សាសីល

សីល សំដៅដល់ការរក្សាកាយ វាចា ចិត្ត ឱ្យល្អប្រពៃ។ សីល នេះមានច្រើនប្រភេទ តែសីលដែលមនុស្សបច្ចុប្បន្ននេះអាចកាន់យកបានយ៉ាងងាយស្រួលនោះ គឺនិច្ចសីល ឬហៅថាសីល៥។ សីល៥ គឺជាការវៀរចាកការធ្វើនូវអំពើអាក្រក់៥យ៉ាង រួមមាន ការមិនសម្លាប់សត្វ១ ការមិនលួចទ្រព្យគេ១ ការមិនប្រព្រឹត្តខុសក្នុងកាមទាំងឡាយ១ ការមិនពោលពាក្យកុហក១ និងការមិនផឹកនូវទឹកស្រវឹង ឬគ្រឿងញៀន១។ អ្នករក្សាសីលរមែងទទួលបាននូវសេចក្តីសុខ សេចក្តីចម្រើន ដូចមានពុទ្ធភាសិតថា "សុខំ យាវ ជរា សីលំ" ដែលមានន័យថា ការរក្សាសីលរមែងនាំមកនូវសេចក្តីសុខដល់ចាស់ជរា។ អ្នករក្សាសីលមិនត្រឹមតែទទួលបានកុសលសម្រាប់ខ្លួនឯងនោះទេ តែក៏កើតជាសេចក្តីចម្រើនដល់សង្គមជាតិផងដែរ ព្រោះថា បើមនុស្សវៀរចាកសេចក្តីអាក្រក់តាមរយៈការរក្សាសីល នឹងធ្វើឱ្យមនុស្សមានការសាមគ្គីគ្នា ដែលជាហេតុធ្វើឱ្យសង្គមមិនមានអសន្តិសុខឡើយ។

**៣-ភាវនាមយៈ បុណ្យកើតអំពីការចម្រើនភាវនា**

បុណ្យដែលសម្រេចដោយការចម្រើនភាវនា សំដៅដល់សេចក្ដីល្អដែលកើតឡើងតាមរយៈការហ្វឹកហាត់អប់រំចិត្តឱ្យសុខស្ងប់ មានគុណធម៌។ ភាវនានេះ មាន២យ៉ាង គឺសមថភាវនា និងវិបស្សនាភាវនា។ សមថភាវនា សំដៅដល់ការធ្វើភាវនាឱ្យចិត្តស្ងប់។ ចំណែក វិបស្សនាភាវនា គឺការធ្វើភាវនាឱ្យមានបញ្ញា។ ការធ្វើភាវនារមែងចម្រើនជាបុណ្យកុសល ព្រោះថា នឹងធ្វើឱ្យចិត្តស្ងប់ មិនគិតចង់ប្រទូស ឬព្យាបាទអ្នកដទៃ និងជាអ្នកដែលចេះគិតគូរបានច្បាស់លាស់មុននឹងជឿ ឬធ្វើអ្វីមួយ។

**៤-អបចាយនមយៈ បុណ្យកើតអំពីការគោរពកោតក្រែងចំពោះបុគ្គលដែលគួរគោរព**

អបចាយនៈ សំដៅដល់ការគោរព ការកោតក្រែង ការបូជា ឬការធ្វើសក្ការៈដល់អ្នកណាម្នាក់ជាដើម។ ការគោរពនេះមាន៥យ៉ាង គឺការក្រាបសំពះ១ ការក្រោកទទួល១ ការរៀបចំកន្លែងឱ្យអង្គុយ១ ការទុកផ្លូវឱ្យដើរ១ និងការធ្វើសក្ការៈបូជា១។ អ្នកដែលមានការគោរពកោតក្រែងនេះ រមែងបានសេចក្ដីសុខ ដូចមានពុទ្ធភាសិតដែលព្រះអង្គសម្ដែងក្នុងមង្គលសូត្រថា "បូជា ច បូជនីយានំ ឯតម្មង្គលមុត្តមំ" ដែលមានន័យថា ការបូជាដល់បុគ្គលដែលគួរបូជា ជាមង្គលដ៏ឧត្តម។ ការគោរពកោតក្រែងគ្នានឹងធ្វើឱ្យមនុស្សចេះសាមគ្គីគ្នា និងមិនមានការឈ្លោះទាស់ទែងគ្នា។

**៥-វេយ្យាវច្ចមយៈ បុណ្យកើតអំពីការជួយខ្វល់ខ្វាយក្នុងកិច្ចការជាកុសល**

វេយ្យាវច្ចៈ សំដៅដល់ការខ្វល់ខ្វាយ ការខ្នះខ្នែង ការយកចិត្តទុកដាក់ និងការមិនប្រចាំគ្នា។ មនុស្សដែលខ្វល់ខ្វាយធ្វើបុណ្យទាន ឬជួយអ្នកដទៃក្នុងការធ្វើសេចក្ដីល្អ នឹងធ្វើឱ្យអ្នកផងទាំងពួងស្រឡាញ់ពេញចិត្ត បើទោះបីជាអ្នកនោះមិនមានទ្រព្យសម្បត្តិច្រើនក៏ដោយ។ បន្ថែមពីលើនេះ មនុស្សដែលចេះខ្វល់ខ្វាយធ្វើអំពើល្អ មិនត្រឹមតែបាននូវបុណ្យកុសលសម្រាប់ខ្លួនឯងនោះទេ ថែមទាំងបានចែករំលែកនូវគំរូល្អដល់អ្នកដទៃ និងសង្គមទាំងមូលទៀតផង។

**៦-បត្តិទានមយៈ បុណ្យកើតអំពីការឱ្យចំណែកបុណ្យដល់អ្នកដទៃ**

បុណ្យកើតអំពីការឱ្យចំណែកបុណ្យដល់អ្នកដទៃ សំដៅដល់ការចែករំលែកនូវសេចក្ដីល្អដល់អ្នកដទៃ។ នៅពេលមនុស្សម្នាក់ចែករំលែកសេចក្ដីល្អ ឬការជាកុសលដល់អ្នកដទៃនោះ បង្ហាញថាគេជាមនុស្សដែលមានចិត្តស្អាតបរិសុទ្ធ ចិត្តពោរពេញដោយកុសល។ អ្នកដែលចែករំលែកនូវបុណ្យដល់អ្នកដទៃនេះ ក៏ឈ្មោះថាបានផ្សាយនូវសេចក្ដីល្អដល់សង្គមផងដែរ។

**៧-បត្តានុមោទនាមយៈ បុណ្យកើតអំពីការអនុមោទនាចំណែកបុណ្យរបស់អ្នកដទៃ**

បុណ្យកើតអំពីការអនុមោទនាចំណែកបុណ្យរបស់អ្នកដទៃ សំដៅដល់ការត្រេកអរចំពោះសេចក្ដីល្អ ឬបុណ្យកុសលដែលអ្នកដទៃបានធ្វើ។ មនុស្សដែលចេះត្រេកអរក្នុងសេចក្ដីល្អរបស់អ្នកដទៃនោះ ជាមនុស្សដែលមានមេត្តា និងជាមនុស្សដែលមិនមានចិត្តប្រទូស ឬគិតចង់ព្យាបាទ ច្រណែនឈ្នានីសអ្នកដទៃឡើយ។

**៨-ធម្មស្សវនមយៈ បុណ្យកើតអំពីការស្ដាប់ធម៌**

ការស្ដាប់ធម៌ ឬស្ដាប់នូវដំបូន្មានផ្សេងៗ រមែងបានជាបុណ្យកុសល ហើយក៏ធ្វើឱ្យមានបញ្ញាផងដែរ។ ការស្ដាប់នេះ នឹងធ្វើឱ្យមនុស្សបានចំណេះដឹងសម្រាប់យកទៅប្រើប្រាស់ក្នុងសង្គមបាន។ ម្យ៉ាងទៀត ការស្ដាប់ធម៌ក៏ធ្វើឱ្យមនុស្សចងចាំបានច្រើនឡើងវិញ នូវអ្វីដែលខ្លួនបានភ្លេច។ អ្នកស្ដាប់ធម៌ ក៏នឹងអាចកម្ចាត់បង់នូវក្ដីសង្ស័យណាមួយដែលខ្លួនបានជួបប្រទះ ហើយលាក់ទុកក្នុងចិត្តនោះ។

### ៩-ធម្មទេសនាមយៈ បុណ្យកើតអំពីការបង្ហាត់បង្រៀនធម៌

ការសម្ដែងធម៌ក្ដី ការបង្រៀនចំណេះដឹងទូទៅក្ដី សុទ្ធតែនាំឱ្យកើតបុណ្យកុសលទាំងអស់។ ការសម្ដែងធម៌ ឬការបង្រៀននេះ គឺជាការចែករំលែកនូវចំណេះដឹងដែលជាទ្រព្យមិនអាចកាត់ថ្លៃបាន។ នៅពេលមនុស្សមានចំណេះដឹង គេនឹងអាចជួយខ្លួនឯង ព្រមទាំងគ្រួសារឱ្យមានសេចក្ដីសុខសុភមង្គល។ អ្នកដែលមានចំណេះដឹង ក៏នឹងធ្វើឱ្យប្រទេសជាតិរីកចម្រើនផងដែរ។

### ១០-ទិដ្ឋុជុកម្ម បុណ្យកើតអំពីការធ្វើទិដ្ឋិឱ្យត្រឹមត្រូវ

ការធ្វើទិដ្ឋិឱ្យត្រឹមត្រូវ មានន័យថា ការតម្រង់ចិត្តគំនិតដែលខ្លួនយល់ខុស ឱ្យងាកបែរមករកផ្លូវត្រូវតាមធម៌ពិតវិញ។ ទិដ្ឋិនេះចែកចេញជា២យ៉ាងគឺ សម្មាទិដ្ឋិ និងមិច្ឆាទិដ្ឋិ។ សម្មាទិដ្ឋិ គឺការយល់ត្រូវតាមធម៌ពិត យល់ដោយបញ្ញា ដូចជាយល់ឃើញថា មនុស្សកើតមកតែងមានចាស់ ឈឺ ស្លាប់ ជាដើម។ ចំណែកមិច្ឆាទិដ្ឋិ សំដៅដល់ការយល់ឃើញខុសអំពីសេចក្ដីពិត ដូចជាយល់ថា មាតាបិតាគ្មានគុណ សត្វស្លាប់ហើយលែងកើតទៀតជាដើម។ បើមនុស្សមានទិដ្ឋិត្រូវ រមែងដឹកនាំអ្នកដទៃឱ្យដើរផ្លូវត្រូវដូចខ្លួនដែរ។

អ្នកដែលបានអប់រំកាយ វាចា ចិត្ត ឱ្យមានសីលធម៌ ដោយបំពេញកុសលធម៌ឱ្យបរិបូណ៌ រមែងមាននូវសេចក្ដីសុខ សប្បាយរីករាយ ទាំងក្នុងលោកនេះ រហូតដល់លោកខាងមុខ ដូចជាពុទ្ធភាសិតថា “ឥធ មោទតិ បេច្ច មោទតិ កតបុញ្ញោ ឧភយត្ថ មោទតិ” ដែលមានន័យថា អ្នកបានធ្វើបុណ្យ រមែងរីករាយសប្បាយក្នុងលោកទាំងពីរ គឺរីករាយសប្បាយក្នុងលោកនេះ លុះទៅកាន់លោកខាងមុខ រមែងរីករាយសប្បាយទៀត។

### គ-សចិត្តបរិយោទបនំ ការញ៉ាំងចិត្តរបស់ខ្លួនឱ្យផូរផង់

ពុទ្ធឱវាទទី៣នេះ មានសេចក្ដីដ៏សុខុមពន់ពេក ព្រោះជាឱវាទដើម្បីជម្រះសម្អាតនូវចិត្ត ដែលប្រឡូកប្រឡំដោយកិលេសឱ្យទៅជាចិត្តស្អាតផូរផង់។ ពិតណាស់ រូបកាយរបស់មនុស្សសត្វទាំងអស់មិនមានធម្មជាតិអ្វីធំជាងចិត្តទេ។ នេះមានន័យថា មានតែធម្មជាតិគឺចិត្ត ជាប្រធាន ឬជាធំជាងអវៈយវៈទាំងអស់។ ចិត្តជាអ្នកបង្គាប់ឱ្យកាយ វាចា ទទួលធ្វើទាំងល្អ ទាំងអាក្រក់។ បើចិត្តល្អ ក៏បង្គាប់ឱ្យធ្វើល្អ ហើយបើចិត្តអាក្រក់ ក៏បង្គាប់ឱ្យធ្វើអាក្រក់។ ប៉ុន្តែធម្មតាចិត្ត កាលបើបានប្រទះអារម្មណ៍ដែលគួររីករាយ ក៏រមែងត្រេកអរ។ កាលបើប្រទះអារម្មណ៍ដែលគួរស្អប់ ក៏អាក់អន់។ កិលេសដែលជាគ្រឿងសៅហ្មងរបស់ចិត្ត ទោះបីមានច្រើនយ៉ាងក៏ពិតមែន ប៉ុន្តែបើនិយាយដោយសង្ខេប មានតែបីយ៉ាងគឺ រាគៈ សេចក្ដីរីករាយត្រេកត្រអាលទៅក្នុងអារម្មណ៍១ ទោសៈ សេចក្ដីខឹងក្រោធគុំគួនព្យាបាទ១ មោហៈ សេចក្ដីវង្វេង ភាន់ច្រឡំ មិនដឹងខុសត្រូវ១។ កិលេសទាំង៣នេះ រមែងធ្វើចិត្តឱ្យប្រឡាក់ ឱ្យសៅហ្មង ប្រៀបដូចទឹកដែលលាយដោយពណ៌ផ្សេងៗមានពណ៌ខ្មៅជាដើម។ វិធីនៃការទូន្មានចិត្តនោះ ពុំមែនធម៌ណាមួយដែលក្រៅអំពីសមថកម្មដ្ឋាននោះទេ ព្រោះសមថកម្មដ្ឋាន លោកសង្គ្រោះថាជាវិធី ឬជាមធ្យោបាយដ៏ប្រសើរសម្រាប់ទូន្មានប្រៀនប្រដៅចិត្ត ដើម្បីឱ្យចិត្តបរិសុទ្ធ ប្រាសចាកគ្រឿងមន្ទិលសៅហ្មង។ ចិត្តរបស់បុគ្គលដែលបានចម្រើនអប់រំរឿយៗ រមែងទៅជាចិត្តបរិសុទ្ធផូរផង់ ជាចិត្តថ្លាស្អាត ផុតចាកមន្ទិលគឺកិលេសគ្រប់យ៉ាង ឈ្មោះថាជាការញ៉ាំងចិត្តរបស់ខ្លួនឱ្យស្អាត។

មនុស្សដែលអាចរក្សាចិត្តបានល្អហើយ តែងអាចធ្វើអំពើល្អដោយប្រពៃ ព្រមទាំងអាចធ្វើការងារអ្វីៗប្រកបដោយជោគជ័យទៀតផង ពោលគឺអ្នកដែលមានការគ្រប់គ្រងចិត្តបានល្អ នឹងមានសេចក្ដីសុខចម្រើន ដូចមានពុទ្ធភាសិតបានសម្ដែងថា “ចិត្តំ គុត្តំ សុខាវហំ” មានន័យថា ចិត្តដែលគេរក្សាល្អហើយ រមែងនាំមកនូវសេចក្ដីសុខ។

### ៣.២- តើព្រះពុទ្ធសាសនាអប់រំមនុស្សដោយមធ្យោបាយអ្វីខ្លះ?

ឱវាទ ឬពាក្យប្រៀនប្រដៅរបស់ព្រះសម្មាសម្ពុទ្ធ ត្រូវបានផ្សព្វផ្សាយដោយព្រះសង្ឃ ដែលជាសាវ័កនៅកៀកជិតនឹងព្រះពុទ្ធដីកា។ បន្ថែមពីលើនេះ ធម៌វិន័យរបស់ព្រះពុទ្ធក៏ត្រូវបានផ្សព្វផ្សាយដោយឧបាសក ឬឧបាសិកា និងពុទ្ធសាសនិកដទៃទៀតផងដែរ។ ការផ្សព្វផ្សាយនូវព្រះពុទ្ធវចនៈដើម្បីឱ្យបានដឹងឮដល់ពុទ្ធបរិស័ទទូទៅ ត្រូវបានធ្វើឡើងតាមមធ្យោបាយជាច្រើន។

#### ក-តាមរយៈការសិក្សាតាមគម្ពីរគោលរបស់ព្រះពុទ្ធសាសនា

ដើម្បីបានចេះដឹងនូវព្រះពុទ្ធដីកា ការសិក្សាតាមគម្ពីរគោលគឺជារឿងសំខាន់បំផុត។ គម្ពីរគោលរបស់ព្រះពុទ្ធសាសនា គឺព្រះត្រៃបិដក។ ទន្ទឹមនឹងនោះ ក៏មានគម្ពីរមួយចំនួនទៀតដូចជា អដ្ឋកថា ដីកា មូលដីកា អនុដីកាជាដើម។ គម្ពីរទាំងនេះ ច្រើនតែត្រូវបានតម្កល់ទុកនៅតាមទីវត្តអារាម ឬតាមទីបូជនីយដ្ឋាននានា។ ពុទ្ធបរិស័ទអាចទៅអានគម្ពីរទាំងនោះនៅវត្តផ្ទាល់ក៏បាន ឬអាចខ្ចីពីព្រះសង្ឃមកអាននៅផ្ទះក៏បាន ឬក៏អាចចូលរៀនជាមួយនឹងវគ្គបណ្តុះបណ្តាលផ្សេងៗដែលបើកបង្រៀនដោយព្រះសង្ឃ និងធម្មាចារ្យនានា។

#### ខ-តាមរយៈការសម្តែងធម្មទេសនាតាមបុណ្យនានា

ការសម្តែងព្រះធម៌ទេសនាតាមបុណ្យនានា គឺមានមកតាំងពីបុរាណកាលមក។ ការសម្តែងធម៌នោះ គឺជាឱកាសមួយក្នុងការផ្សព្វផ្សាយនូវព្រះឱវាទរបស់ព្រះសម្មាសម្ពុទ្ធដល់ពុទ្ធបរិស័ទ។ អង្គធម្មកថិកដែលសម្តែងព្រះធម៌តាមបុណ្យនានានោះ លោកច្រើនតែអប់រំឱ្យចេះធ្វើទាន រក្សាសីល និងឱ្យកូនចៅចេះគោរពមាតាបិតាជាដើម ដែលជារឿងល្អខ្លាំងសម្រាប់មនុស្សក្នុងសង្គម។ បន្ថែមពីលើនេះ ក៏មានអង្គធម្មកថិកខ្លះដែលឆ្លាតឈ្លាស លោកអាចលើកយកនូវព្រះពុទ្ធវចនៈផ្សេងៗក្រៅអំពីទាន និងសីល មកសម្តែងដែលជាហេតុធ្វើឱ្យពុទ្ធបរិស័ទមានឱកាសកាន់តែល្អក្នុងការបានដឹងអំពីព្រះពុទ្ធសាសនា។

#### គ-តាមរយៈការធ្វើបុណ្យបែបព្រះពុទ្ធសាសនាសុទ្ធ

ក្រៅពីបានស្តាប់ បានរៀនព្រះធម៌របស់ព្រះពុទ្ធតាមរយៈការស្តាប់ព្រះធម៌ទេសនានៅតាមផ្ទះនោះ ពុទ្ធបរិស័ទក៏អាចសិក្សាស្តាប់នូវព្រះធម៌នោះ នៅក្នុងវត្តពេលមានកម្មវិធីបុណ្យបែបព្រះពុទ្ធសាសនាសុទ្ធផងដែរ។ បុណ្យបែបព្រះពុទ្ធសាសនាសុទ្ធ សំដៅដល់បុណ្យវិសាខបូជា បុណ្យមាឃបូជា និងបុណ្យអាសាឡ្ហបូជាជាដើម។ បុណ្យទាំងអស់នេះ មិនត្រឹមតែមានព្រះធម្មកថិកសម្តែងធម៌នោះទេ ថែមទាំងកន្លែងខ្លះ មានរៀបចំវេទិកាបរិយាយអំពីគុណមាតាបិតាដើម្បីឱ្យពុទ្ធបរិស័ទ និងសិស្សសាលាជាដើមបានស្តាប់ទៀតផង។

#### ឃ-តាមរយៈការសហការបង្រៀនរបស់ព្រះសង្ឃជាមួយគ្រឹះស្ថានអប់រំនានា

ពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធ ក៏ត្រូវបានផ្សព្វផ្សាយតាមរយៈការសហការរបស់ព្រះសង្ឃ និងសាលារៀនមួយចំនួនដែរ។ តាមការសង្កេតកន្លងមក ឃើញថាមានសាលារៀនមួយចំនួនបានអនុញ្ញាត និងនិមន្តព្រះសង្ឃដើម្បីជួយបង្រៀនអក្សរ ឬបង្រៀនសីលធម៌ដល់សិស្សានុសិស្ស។ ទន្ទឹមនឹងនោះ ក៏មានសាលាខ្លះបានបង្កើតវេទិកាអប់រំសីលធម៌ដល់សិស្សតែម្តង។ ជាឧទាហរណ៍ នៅខេត្តបាត់ដំបង យើងឃើញថាមានព្រះបញ្ញាមុនីញាណ ហាក់ សៀងហៃ លោកបានបង្កើតជាអង្គការពុទ្ធសាសនាដើម្បីការអប់រំនៃកម្ពុជា ហើយបានជួយសង្គមយ៉ាងច្រើន។ ជាក់ស្តែង លោកបានសហការជាមួយសាលាបឋមមួយចំនួន មានសាលាបឋមសិក្សាវត្តកំផែងជាដើម ដើម្បីបង្រៀនអក្សរ បង្រៀនធម៌ និងបង្រៀនសីលធម៌ដល់សិស្សានុសិស្ស។ នេះគឺជាឱកាសល្អមួយដែលព្រះសង្ឃអាចផ្សាយនូវពុទ្ធវចនៈដល់មនុស្សដែលស្ថិតក្នុងបឋមវ័យ ឬវ័យនៅក្មេងៗ។

**ខ-តាមរយៈប្រព័ន្ធផ្សព្វផ្សាយ ឬបណ្ដាញសង្គមនានា**

សព្វថ្ងៃនេះ បច្ចេកវិទ្យាមានការរីកចម្រើន។ ព័ត៌មានផ្សេងៗ គេលែងសូវផ្សាយតាមកាសែតជាសន្លឹកក្រដាសទៀតហើយ គឺច្រើនប្រើប្រព័ន្ធផ្សព្វផ្សាយ ដូចជាទូរទស្សន៍ និងវិទ្យុជាដើម។ ទន្ទឹមនឹងនោះ ការផ្សាយតាមបណ្ដាញសង្គមនានាមានហ្វេសប៊ុក និងយូធូបជាដើមកាន់តែមានការពេញនិយម។ ក្នុងបរិបទនេះ យើងឃើញថា មានព្រះសង្ឃ និងពុទ្ធបរិស័ទជាច្រើនបានចូលរួមផ្សព្វផ្សាយនូវឱវាទរបស់ព្រះសម្មាសម្ពុទ្ធតាមរយៈប្រព័ន្ធទាំងអស់នោះ។ ជាក់ស្ដែង ព្រះសង្ឃ និងពុទ្ធបរិស័ទមួយចំនួនបានបង្ហោះចែករំលែករូបភាព ឬវីដេអូមេរៀនរបស់ព្រះសម្មាសម្ពុទ្ធរហូតមានគេស្គាល់ច្រើន និងមានពុទ្ធបរិស័ទបានសិក្សាច្រើនផងដែរ។

**ច-តាមរយៈការលើកស្លាក ឬបដាផ្សេងៗ**

ការលើកស្លាក ឬចងបដាអំពីពុទ្ធវចនៈ តាមទីវត្តអារាម ឬទីសាធារណៈផ្សេងៗ ក៏ជាមធ្យោបាយមួយក្នុងការផ្សព្វផ្សាយនូវព្រះធម៌របស់ព្រះពុទ្ធ។ យើងឃើញថា នៅតាមវត្តខ្លះបានរៀបចំយ៉ាងស្អាត ព្រមទាំងមានសួនច្បារគួរជាទីរីករាយ។ ទន្ទឹមនឹងនោះ គណៈគ្រប់គ្រងវត្តមានព្រះគ្រូចៅអធិការវត្តជាដើម បានតុបតែងទីនោះដោយមានសរសេរនូវពាក្យស្លោក ពាក្យអប់រំ និងពុទ្ធគាថាផងដែរ។

**ឆ-តាមរយៈអក្សរសិល្ប៍**

អក្សរសិល្ប៍ គឺជាចំណែកមួយក្នុងការផ្សព្វផ្សាយអប់រំអ្នកសិក្សាឱ្យស្គាល់ពីព្រះពុទ្ធវចនៈ ឬបានដឹងអំពីទ្រឹស្ដីរបស់ព្រះពុទ្ធសាសនា។ ក្នុងប្រទេសខ្មែរយើង បានចាត់ទុករឿងជាតក ឬរឿងដែលត្រូវបានគេនិពន្ធឡើងជំនាន់ក្រោយ ហើយមានការផ្សាយអំពីគោលគំនិតអប់រំតាមបែបព្រះពុទ្ធសាសនា ថាជាអក្សរសិល្ប៍ពុទ្ធនិយម។ គេចែករឿងពុទ្ធនិយមជា៣គឺ ពុទ្ធនិយមសុទ្ធ ពុទ្ធនិយមក្លាយ និងពុទ្ធនិយមក្លាយហួសហេតុ។ អក្សរសិល្ប៍ពុទ្ធនិយមសុទ្ធ គឺសំដៅដល់រឿងទសជាតក ដែលជារឿងមានសម្ដែងក្នុងបិដកពិតៗ ពោលគឺដកស្រង់ចេញពីសុត្តន្តបិដកភាគ៦២ និងភាគ៦៣។ រីឯអក្សរសិល្ប៍ពុទ្ធនិយមក្លាយ គឺសំដៅដល់រឿងទាំង៥០ដែលមាននៅក្នុងសៀវភៅបញ្ញាសជាតក។ តាមការស្រាវជ្រាវ រឿងក្នុងបញ្ញាសជាតកត្រូវបាននិពន្ធឡើងក្នុងអំឡុងព.ស.២០០០-២២០០ គឺរវាងគ.ស.១៤៥៧-១៦៥៧ ដោយសារភិក្ខុសង្ឃខ្មែរ ថៃ លាវ ភូមា ចេញទៅសិក្សាធម្មវិន័យនៅលង្កាទ្វីប ហើយមកស្រុករបស់ខ្លួនវិញ ក៏បាននិពន្ធរឿងតាមទំនងនិទានជាតក។ ចំណែកអក្សរសិល្ប៍ពុទ្ធនិយមក្លាយហួសហេតុ សំដៅដល់រឿងដែលគេនិពន្ធនៅសម័យក្រោយ ហើយមានបង្ហាញពីកាលបរិច្ឆេទ និងឈ្មោះអ្នកនិពន្ធច្បាស់លាស់ មានដូចជារឿងព្រះចន្ទគោរព រឿងមរណមាតា និងរឿងកាកីជាដើម។ រឿងបែបពុទ្ធនិយមនេះ ត្រូវបានប្រជាជនខ្មែរនិទានប្រាប់កូនចៅនៅពេលទំនេរ ហើយក៏ត្រូវក្រសួងអប់រំ យុវជន និងកីឡា បានបញ្ចូលទៅក្នុងកម្មវិធីផងដែរ។

ការសិក្សានូវអក្សរសិល្ប៍ទាំងនេះ ក៏បានធ្វើឱ្យអ្នកសិក្សាទទួលបានចំណេះដឹង និងការអប់រំពីគោលទ្រឹស្ដីនៃព្រះពុទ្ធសាសនាទៀតផង។ ជាឧទាហរណ៍ ក្នុងរឿងព្រះវេស្សន្តរបានអប់រំមនុស្សអំពីការធ្វើទាន។ ការធ្វើទានរបស់ព្រះអង្គ គឺដើម្បីចែករំលែកនូវសេចក្ដីសុខដល់អ្នកដទៃ។ កាលណាយើងចេះចែកគ្នារស់បែបនេះ ស្រុកទេសនឹងមានការសាមគ្គីគ្នា ហើយបានជាកម្លាំងដ៏ខ្លាំងសម្រាប់កសាងជាតិ។ ក្នុងរឿងដដែលនេះក៏បានអប់រំឱ្យយើងចេះដោះស្រាយនូវបញ្ហាដោយសន្តិវិធីដើម្បីសុខសន្តិភាពរបស់ជាតិផងដែរ។ ជាតួយ៉ាងពេលដែលព្រះវេស្សន្តរឱ្យដំរីមង្គលទៅពួកអ្នកស្រុកក្លឹង្គរាស្ត្រនោះ បានធ្វើឱ្យពួកអ្នកស្រីពិរាស្ត្រខឹងសម្បាយ៉ាងខ្លាំង ហើយសុំព្រះបាទស្រីសញ្ជ័យឱ្យបំបរបង់ព្រះវេស្សន្តរទៅបួសនៅភ្នំគិរីវង្កត។ ព្រះបាទស្រីសញ្ជ័យបាន

គោរពតាមការស្នើសុំរបស់ប្រជារាស្ត្រដោយឱ្យព្រះវេស្សន្តរចេញទៅបួស។ នេះបញ្ជាក់ថា ព្រះបាទស្រីសញ្ជ័យបានដោះស្រាយបញ្ហាដោយសន្តិវិធី និងយកមតិរបស់រាស្ត្រជាធំ ហើយនេះ គឺស្របទៅនឹងការដឹកនាំតាមបែបប្រជាធិបតេយ្យ។ ចំណែកក្នុងរឿងសុវណ្ណសាមវិញ បានបង្ហាញពីការដឹងគុណ និងការគោរពមាតាបិតារបស់សុវណ្ណសាម។ នៅពេលដែលអ្នកមានគុណទាំងពីរត្រូវបានពស់ព្រួសពិសខ្វាក់ភ្នែកនោះ សុវណ្ណសាមបានរ៉ាប់រងចិញ្ចឹមលោកទាំងពីរដោយស្ម័គ្រស្មោះបំផុត។ ចំណុចនេះ បានបង្ហាញថា ការគោរពមាតាបិតា គឺជាកាតព្វកិច្ចរបស់កូន ហើយក៏ជាចរិយាធម៌មួយដែលជួយឱ្យគ្រួសារមានសេចក្តីសុខសុភមង្គល និងបានធ្វើឱ្យសង្គមមានសេចក្តីថ្លៃថ្នូរ។ រីឯរឿងមហាជនកវិញ បានអប់រំឱ្យមានសេចក្តីព្យាយាម។ ព្រះហាជនកបានទៅរកស៊ីតាមឈ្នួញសំពៅ ហើយត្រូវជួបគ្រោះលិចសំពៅនោះ ព្រះមហាជនកពោធិសត្វបានឡើងឈរលើចុងក្តោងឆ្ពោះព្រះភក្រ្តទៅនគរមិថិលា ហើយក៏លោតផ្លោងរំលងពួកត្រី និងអណ្តើកហែលទៅអស់រយៈពេល៧ថ្ងៃ។ នាងមណីមេខលាជាទេវធីតារក្សាសមុទ្រ ឃើញថាព្រះមហាជនកជាអ្នកមានសេចក្តីព្យាយាម និងជាអ្នកបម្រើម្តាយ នាងមណីមេខលាក៏ស្រង់ព្រះពោធិសត្វទៅដាក់នៅនគរមិថិលាទៅ។ នៅទីបំផុតព្រះមហាជនកបានគ្រងរាជ្យជាស្តេចនៅនគរមិថិលាហើយខំបំពេញបុណ្យកុសលមានការធ្វើទាន និងការចេញបួសជាដើម។

ជារួមមក អក្សរសិល្ប៍ពុទ្ធនិយម បានលើកយកអំពីចរិយា គឺការប្រព្រឹត្តរបស់ព្រះបរមពោធិសត្វដែលព្រះអង្គខំប្រឹងប្រតិបត្តិក្នុងអតីតជាតិដើម្បីឱ្យបានសម្រេចនូវការត្រាស់ដឹង។ អាស្រ័យដោយបានសិក្សា បានស្តាប់នូវរឿងទាំងអស់នេះ ធ្វើឱ្យប្រជាជនខ្មែរយកជាគតិ និងជាគំរូក្នុងការប្រព្រឹត្តនូវអំពើល្អដែលធ្វើឱ្យខ្លួនរស់នៅក្នុងសេចក្តីសុខ សុភមង្គលក្នុងជីវិត ព្រមទាំងបានជាប្រយោជន៍ក្នុងបរលោកផងដែរ។

### ៣.៣- តើព្រះពុទ្ធសាសនាលើកកម្ពស់ការអប់រំសីលធម៌ និងចរិយាធម៌ដូចម្តេចខ្លះ?

បន្ទាប់ពីបានឃើញនូវមេរៀនរបស់ព្រះសម្មាសម្ពុទ្ធ និងមធ្យោបាយនៃការផ្សព្វផ្សាយនូវព្រះពុទ្ធវចនៈហើយ យើងងាកមកមើលពីការចូលរួមរបស់ព្រះពុទ្ធសាសនាក្នុងការលើកកម្ពស់ការអប់រំសីលធម៌ និងចរិយាធម៌វិញម្តង។ ព្រះពុទ្ធសាសនាពិតជាបានចូលរួមចំណែកច្រើនក្នុងការអប់រំឱ្យមនុស្សមានសីលធម៌ និងចរិយាធម៌ តាមរយៈគោលធម៌របស់ព្រះពុទ្ធ។

**ក-សីលធម៌**

សីលធម៌ សំដៅដល់ទ្រឹស្តី និងពាក្យទូន្មានសម្រាប់បង្រៀនមនុស្សឱ្យធ្វើនូវអំពើល្អដោយកាយ វាចា និងចិត្ត។ ក្នុងសៀវភៅសិក្សាសង្គម ថ្នាក់ទី១០ របស់ក្រសួងអប់រំ យុវជន និងកីឡាបានលើកឡើងថា “ក្នុងដំណើរជីវិតរស់នៅប្រចាំថ្ងៃ មនុស្សគ្រប់រូបប្រកាន់សីលធម៌៤យ៉ាង គឺ សីលធម៌ផ្ទាល់ខ្លួន សីលធម៌ក្នុងគ្រួសារ សីលធម៌ក្នុងវិជ្ជាជីវៈ និងសីលធម៌ក្នុងសង្គម”។ ចំណែកសៀវភៅសីលធម៌-ពលរដ្ឋវិជ្ជា ថ្នាក់ទី១២ របស់ក្រសួងអប់រំ យុវជន និងកីឡាបានលើកឡើងនូវសីលធម៌មួយទៀត នោះគឺ “សីលធម៌សកល” ដែលជាសីលធម៌រួមរបស់មនុស្ស។ ក្នុងព្រះពុទ្ធសាសនា មានព្រះពុទ្ធឱវាទ ឬពាក្យប្រៀនប្រដៅជាច្រើនសម្រាប់បង្រៀនអប់រំមនុស្សឱ្យបានយល់ដឹងអំពីសីលធម៌ទាំងនោះ។

**១-សីលធម៌ផ្ទាល់ខ្លួន**

សីលធម៌ផ្ទាល់ខ្លួន សំដៅដល់ការបានយល់ដឹងខុសត្រូវ ស្គាល់ល្អ ស្គាល់អាក្រក់ ការទទួលខុសត្រូវចំពោះអំពើរបស់ខ្លួន និងដឹងខ្លួនថាត្រូវលះបង់អំពើអបាយមុខផ្សេងៗ និយាយស្តីឱ្យមានប្រយោជន៍ មិន

និយាយកុហក មិននិយាយញុះញង់ជាដើម។ ដើម្បីឱ្យមានសីលធម៌ផ្ទាល់ខ្លួននេះ ក្នុងព្រះពុទ្ធសាសនាបានបង្រៀនមនុស្សឱ្យប្រតិបត្តិនូវធម៌ទាំងឡាយ មានឃរាវាសធម៌ និងកល្យាណធម៌ជាដើមដើម្បីឱ្យមនុស្សបានដឹងនូវគោលការណ៍នៃការធ្វើខ្លួនឱ្យក្លាយជាមនុស្សល្អ។ ឃរាវាសធម៌ មានន័យថា ធម៌សម្រាប់អ្នកគ្រងផ្ទះ។ ឃរាវាសធម៌នេះមាន៤យ៉ាង គឺសច្ចៈ១ ទមៈ១ ខន្តិ១ និងចាគៈ១។ សច្ចៈ គឺការទៀងត្រង់ ឬស្មោះត្រង់ចំពោះគ្រួសារ ស្មោះត្រង់ចំពោះអ្នកដទៃ និងស្មោះត្រង់ចំពោះសង្គមជាតិ។ មនុស្សស្មោះត្រង់ ទោះធ្វើការងារអ្វីក៏គេទុកចិត្ត។ ទមៈ មានន័យថា ការអប់រំខ្លួន ទប់ខ្លួន ហ្វឹកហាត់ខ្លួនឱ្យស្ទាត់ជំនាញក្នុងកិច្ចការផ្សេងៗក្តី ទប់ចិត្តកុំឱ្យកិលេសអូសទាញទៅក្នុងផ្លូវអាក្រក់ក្តី។ អ្នកដែលឃុំគ្រងចិត្តបានល្អ គឺតែងធ្វើអំពើដែលជាប្រយោជន៍ និងអំពើដែលមិនប៉ះពាល់ដល់អ្នកដទៃ។ ខន្តិ គឺសេចក្តីអត់ធន់ តស៊ូនឹងក្តៅត្រជាក់ អត់ទ្រាំចំពោះការស្រេកឃ្លាន អត់ធន់នឹងការឈឺថ្កាត់ និងអត់ទ្រាំចំពោះសេចក្តីក្រោធផ្សេងៗ។ អ្នកដែលមានសេចក្តីអត់ធន់ នឹងជួយឱ្យខ្លួនឯងធ្វើការងារអ្វីក៏ទទួលបានជោគជ័យ ហើយការខន្តី ក៏នឹងបង្រ្កាបចិត្តខឹងមិនឱ្យបង្កទៅជាហិង្សាផងដែរ។ ចាគៈ គឺការចំណាយទ្រព្យសម្បត្តិធ្វើជាទានដល់អ្នកដទៃ និងការលះបង់ទ្រព្យដើម្បីចិញ្ចឹមមាតាបិតា កូនប្រពន្ធ។ អ្នកដែលចេះធ្វើទាន គឺមិនត្រឹមតែជាបុណ្យកុសលសម្រាប់ខ្លួនឯងនោះទេ តែជាការចែករំលែកនូវសេចក្តីសុខដល់អ្នកដទៃ និងបង្ហាញភាពគំរូរបស់ខ្លួនទៀតផង។ អ្នកដែលមានឃរាវាសធម៌ទាំង៤នេះ នឹងធ្វើឱ្យអ្នកដទៃស្រឡាញ់ចូលចិត្ត ព្រមទាំងបង្កើតនូវសេចក្តីសុខចម្រើនដល់ខ្លួនឯង និងដល់អ្នកដទៃ។ ទន្ទឹមនឹងនេះ ក្នុងព្រះពុទ្ធសាសនាក៏មានសម្តែងអំពីធម៌សម្រាប់កសាងខ្លួនឱ្យក្លាយជាមនុស្សល្អដែរហៅថា កល្យាណធម៌។ កល្យាណធម៌ ប្រែថា ធម៌សម្រាប់មនុស្សល្អ មាន៥យ៉ាង គឺមេត្តា១ សម្មាអាជីវៈ១ សទារសន្តោសៈ១ សច្ចៈ១ សតិ១។ មេត្តា គឺការរាប់អានអាណិតស្រឡាញ់ ចង់ឱ្យគេបានសុខ ចង់ឱ្យគេរួចចាកទុក្ខ។ សម្មាអាជីវៈ មានន័យថាការចិញ្ចឹមជីវិតដោយប្រពៃ មិនប្រាសចាកនឹងច្បាប់សាសនា និងច្បាប់ប្រទេស។ សទារសន្តោសៈ សំដៅដល់ការត្រេកអរពេញចិត្តនឹងគ្រួសាររបស់ខ្លួន។ សច្ចៈ មានន័យថាការប្រព្រឹត្តខ្លួនឱ្យជាមនុស្សពិតត្រង់។ សតិ គឺការមានសេចក្តីភ្ញាក់រឭកជានិច្ច ដឹងខ្លួនជានិច្ចថាខ្លួនកំពុងធ្វើអ្វី។ បន្ថែមពីលើនេះ ព្រះពុទ្ធក៏បានបង្រៀនយើងឱ្យវៀរចាកនូវអបាយមុខទាំង៦យ៉ាង ដែលជាហេតុធ្វើឱ្យមនុស្សបាត់បង់នូវភាពថ្លៃថ្នូរ។ អបាយមុខទាំង៦នោះគឺ ការផឹកទឹកស្រវឹង និងសេពគ្រឿងញៀន១ ការដើរលេងយប់១ ការដើរមើលល្បែង១ ការលេងល្បែងភ្នាល់គ្នា១ ការយកមិត្តអាក្រក់ធ្វើជាមិត្ត១ និងការខ្ជិលច្រអូស១។ ការលះបង់នូវធម៌ទាំង៦ប្រការនេះ នឹងធ្វើឱ្យយើងរស់នៅក្នុងសេចក្តីសុខចម្រើន ប្រកបដោយកិត្តិយសប្រពៃថ្លៃថ្លា។ ក្នុងការលើកកម្ពស់សីលធម៌ផ្ទាល់ខ្លួននេះ ព្រះពុទ្ធក៏បានឱ្យមនុស្សរក្សាសីល ឬហៅថាលះបង់នូវបញ្ចវេរា ពោលគឺវៀរចាកនូវអំពើដែលនាំឱ្យមានកម្មពៀរទាំង៥។ បញ្ចវេរាទាំងនោះមាន ការបៀតបៀនកាប់សម្លាប់សត្វមានជីវិត១ ការបន្លំលួចទ្រព្យអ្នកដទៃ១ ការប្រព្រឹត្តខុសក្នុងកាមទាំងឡាយ មានល្មើសលើប្តីប្រពន្ធគេ១ ការពោលនូវពាក្យភូតភរកុហក១ ការផឹកសុរា និងមេរ័យ១។ ការវៀរចាកនូវបញ្ចវេរានេះ នឹងធ្វើឱ្យមនុស្សមានមេត្តា មានការសាមគ្គី មិនមានហិង្សា ព្រមទាំងការចូលរួមលើកម្ពស់ដល់សិទ្ធិមនុស្ស មានសិទ្ធិនៃការរស់រានមានជីវិត សិទ្ធិទទួលបានព័ត៌មានពិត សិទ្ធិរស់នៅដោយស្មោះស្ម័គ្រក្នុងភាពជាប្តីមួយប្រពន្ធមួយជាដើមផងដែរ។ គោលធម៌ទាំងអស់ដែលបានលើកមកនេះ បង្ហាញយ៉ាងច្បាស់ថា ព្រះពុទ្ធសាសនាបានសម្តែងនូវឱវាទនានាជាច្រើនដែលធ្វើឱ្យមនុស្សមានសីលធម៌ និងយកទៅប្រតិបត្តិ ដើម្បីបង្កើតនូវសេចក្តីសុខចម្រើនដល់ខ្លួន ដល់គ្រួសារ និងធ្វើឱ្យសង្គមរីកចម្រើនរុងរឿងទៀតផង។

## ២-សីលធម៌ក្នុងគ្រួសារ

សីលធម៌ក្នុងគ្រួសារសំដៅដល់ការយល់ដឹងអំពីតួនាទីរបស់ឪពុកម្ដាយក្នុងការអប់រំ មើលថែ និងស្រឡាញ់កូនស្មើៗគ្នា។ ទន្ទឹមនឹងនោះ សីលធម៌ក្នុងគ្រួសារ ក៏សំដៅដល់ការយល់ដឹងនូវវិធីប្រតិបត្តិចំពោះមាតាបិតា ការដឹងគុណ ការស្ដាប់ដំបូន្មាន និងការចិញ្ចឹមបីបាច់ថែរក្សាឪពុកម្ដាយជាដើម។ ចំណែកប្ដីប្រពន្ធដែលចេះដឹងតួនាទីថាត្រូវសាមគ្គីគ្នា មានភក្ដីភាព និងការរស់នៅឱ្យមានសេចក្ដីសុខសុភមង្គលនោះ ក៏ហៅថាសីលធម៌ក្នុងគ្រួសារដែរ។ គ្រួសារ សំដៅដល់ក្រុមមនុស្សដែលមានចំណងទាក់ទងនឹងគ្នាដោយសារកំណើត អាពាហ៍ពិពាហ៍ ការទទួលចិញ្ចឹម ហើយរស់នៅជាមួយគ្នាដូចជា ឪពុកម្ដាយ កូន ប្ដី និងប្រពន្ធ។ ដើម្បីឱ្យគ្រួសាររស់នៅមានសេចក្ដីសុខសុភមង្គលប្រកបដោយសីលធម៌ ព្រះសម្មាសម្ពុទ្ធក៏បានសម្ដែងអំពីសីលធម៌សម្រាប់គ្រួសារផងដែរ។ ព្រះពុទ្ធបានសម្ដែងថា មាតាបិតាត្រូវមានធម៌៥យ៉ាងចំពោះកូន គឺ ហាមកូនមិនឱ្យធ្វើអាក្រក់១ បង្រៀនកូនឱ្យធ្វើល្អ១ ឱ្យកូនបានសិក្សារៀនសូត្រ១ រៀបចំឱ្យកូនមានគូស្រករ១ និងចែកមរតកតាមសមគួរដល់កូន១។ ចំណែកកូន ក៏ត្រូវប្រតិបត្តិនូវធម៌៥យ៉ាងចំពោះឪពុកម្ដាយវិញដែរ គឺ ចិញ្ចឹមមាតាបិតា១ ជួយធ្វើកិច្ចការងារមាតាបិតា១ ការរក្សាពូជពង្សវង្សត្រកូលឱ្យល្អ១ ធ្វើខ្លួនជាកូនល្អឱ្យសមជាអ្នកត្រូវទទួលមរតក១ និងការធ្វើទក្ខិណាទានដល់មាតាបិតាដែលបានស្លាប់ទៅហើយ១។ តាមរយៈធម៌ទាំងនោះ គឺព្រះសម្មាសម្ពុទ្ធបានឱ្យកូនគោរពឪពុកម្ដាយប្រកបដោយសីលធម៌ តាំងពីឪពុកម្ដាយនៅរស់ រហូតដល់ឪពុកម្ដាយស្លាប់ទៅ ក៏កូនត្រូវនឹកដល់គុណលោកទាំងពីរជានិច្ច។ ចំណែកប្ដី និងប្រពន្ធវិញ ក៏ព្រះសម្មាសម្ពុទ្ធបានសម្ដែងនូវធម៌សម្រាប់ឱ្យប្ដីប្រពន្ធប្រតិបត្តិដើម្បីឱ្យមានសីលធម៌ដែរ។ ប្ដីត្រូវមានធម៌៥ប្រការចំពោះប្រពន្ធ គឺការរាប់អានជាប្រពន្ធពេញសិទ្ធិ១ មិនមើលងាយប្រពន្ធ១ មិនក្បត់ប្រពន្ធ១ ប្រគល់សិទ្ធិឱ្យជាធំក្នុងផ្ទះ១ និងឱ្យគ្រឿងអលង្ការតុបតែងកាយដល់ប្រពន្ធ១។ ទន្ទឹមនឹងនោះ ប្រពន្ធក៏ត្រូវមានធម៌៥យ៉ាង ដើម្បីប្រតិបត្តិចំពោះប្ដីផងដែរ គឺ ចាត់ចែងការងារផ្ទះឱ្យបានល្អ១ រាប់អានញាតិទាំងសងខាង១ មិនក្បត់ប្ដី១ ថែរក្សាទ្រព្យឱ្យបានល្អ១ និងឈ្លាសវៃ មិនខ្ជិលច្រអូស១។ ប្ដីប្រពន្ធដែលប្រតិបត្តិតាមសីលធម៌របស់ខ្លួន នឹងធ្វើឱ្យគ្រួសាររស់នៅយ៉ាងមានសេចក្ដីសុខចម្រើន និងសុភមង្គល។ តាមរយៈសីលធម៌ទាំងនេះ ជាអំណះអំណាងមិនអាចប្រកែកបានថា ព្រះពុទ្ធសាសនាពិតជាបានលើកម្កស់ដល់សីលធម៌ក្នុងគ្រួសារយ៉ាងពិតប្រាកដ។

## ៣-សីលធម៌ក្នុងវិជ្ជាជីវៈ

វិជ្ជាជីវៈ សំដៅដល់មុខរបរ ឬការងាររកស៊ីចិញ្ចឹមជីវិតប្រចាំថ្ងៃ។ សីលធម៌ក្នុងវិជ្ជាជីវៈ គឺការយល់ដឹងថាអ្នករកស៊ីត្រូវរកស៊ីប្រកបដោយសេចក្ដីល្អ ជាមុខរបរសុចរិត មិនលួចឆក់ប្លន់ មិនភូតភរបោកប្រាស់ មិនរំលោភបំពានអ្នកដទៃ និងការធ្វើការងារដែលស្របទៅនឹងច្បាប់សង្គម។ ដើម្បីឱ្យការរកស៊ីប្រកបដោយសីលធម៌ ព្រះសម្មសម្ពុទ្ធបានបង្រៀនឱ្យមនុស្សរកស៊ីដោយសម្មាអាជីវោ ឬសម្មាអាជីវៈ មានន័យថាចិញ្ចឹមជីវិតដោយត្រឹមត្រូវ។ ដើម្បីឱ្យការចិញ្ចឹមជីវិតប្រកបដោយធម៌នោះ អ្នករកស៊ីត្រូវតែលះបង់ចោលនូវការរកស៊ីបែបមិច្ឆាជីវៈ។ មិច្ឆាជីវៈ គឺការរកស៊ីចិញ្ចឹមជីវិតដោយប្រាសចាកគន្លងធម៌។ មិច្ឆាជីវៈមាន៥យ៉ាង គឺ សត្ថវណិជ្ជា ជួញដូរគ្រឿងសាស្ត្រាវុធ ឬគ្រឿងផ្ទុះ១ សត្តវណិជ្ជា ជួញដូរមនុស្ស១ មំសវណិជ្ជា ចិញ្ចឹមសត្វដើម្បីលក់សាច់១ មជ្ជវណិជ្ជា ជួញគ្រឿងស្រវឹង១ វិសវណិជ្ជា ជួញថ្នាំពុល១។ ទាក់ទងនឹងការរកស៊ីនេះ ព្រះសម្មាសម្ពុទ្ធក៏បានសម្ដែងនូវធម៌ ដែលជួយឱ្យការងារសម្រេចជោគជ័យ និងជាសីលធម៌មួយក្នុងការចិញ្ចឹមជីវិតផងដែរ នោះគឺឥទ្ធិបាទធម៌។ ឥទ្ធិបាទធម៌ មានន័យថា ធម៌ធ្វើឱ្យសម្រេចប្រយោជន៍គ្រប់យ៉ាង។ ឥទ្ធិបាទធម៌មាន៤យ៉ាងគឺ

ឆន្ទៈ មានសេចក្តីពេញចិត្តចំពោះការងារ១ វីរិយៈ ព្យាយាមធ្វើការងារ១ ចិត្ត គឺយកចិត្តទុកដាក់ធ្វើការងារ១ និងវិមំសា ត្រូវត្រិះរិះពិចារណារកដំណោះស្រាយដើម្បីឱ្យការងារបានរីកចម្រើន១។ ធម៌ទាំងអស់នេះ នឹងធ្វើឱ្យមនុស្សទទួលជោគជ័យក្នុងរកស៊ីចិញ្ចឹមជីវិត និងរស់នៅប្រកបដោយសេចក្តីសុខសប្បាយ។

សីលធម៌ក្នុងវិជ្ជាជីវៈនេះ ក្នុងពុទ្ធសាសនាក៏មានសម្តែងអំពីតួនាទីគ្រូបង្រៀន តួនាទីសិស្ស តួនាទីថៅហ្វាយនាយ និងតួនាទីអ្នកបម្រើ ឬកម្មករផងដែរ។ តាមទ្រឹស្តីរបស់ព្រះពុទ្ធសាសនា គ្រូបង្រៀនត្រូវមានតួនាទី៥យ៉ាង គឺ ដឹកនាំសិស្សឱ្យធ្វើអំពើល្អ១ បង្រៀនសិស្សឱ្យល្អ១ ប្រៀនប្រដៅសិស្សឱ្យចេះគ្រប់សិល្បសាស្ត្រ១ លើកតម្កើងសិស្សក្នុងទីប្រជុំជន១ ការពារសិស្សគ្រប់ទិសទី១។ ចំណែកសិស្សវិញ ក៏ត្រូវមានតួនាទី៥យ៉ាងដើម្បីតបចំពោះសេចក្តីល្អរបស់លោកគ្រូអ្នកគ្រូដែរ។ តួនាទីរបស់សិស្សមាន៥យ៉ាង គឺ ការក្រោកទទួល១ ការជួយបម្រើ ឬជួយធ្វើកិច្ចការរបស់គ្រូ១ ការជឿស្តាប់ឱវាទដោយគោរព១ ការទំនុកបម្រុងគ្រប់មធ្យោបាយដូចជាពេលមានជំងឺ១ ប្រឹងរៀនសិល្បសាស្ត្រដោយគោរព១។ ការប្រតិបត្តិតាមធម៌ទាំងនេះ នឹងធ្វើឱ្យអ្នកទាំងនោះក្លាយជាគ្រូល្អ និងជាកូនសិស្សល្អ សិស្សដែលចេះដឹងគុណគ្រូបង្រៀន។ ចំណែក ការងារក្នុងសង្គមដទៃទៀត មនុស្សយើងមានតួនាទីផ្សេងៗគ្នា ដោយអ្នកខ្លះជាថៅហ្វាយនាយ និងអ្នកខ្លះជាកម្មករគេ។ ដើម្បីឱ្យការងារទាំងនោះមានការរីកចម្រើន និងកម្មករមានសិទ្ធិសេរីភាពស្របតាមច្បាប់ការងារនោះ ការគោរពតួនាទីក្នុងភាពជាម្ចាស់ និងភាពជាកម្មករ គឺជារឿងសំខាន់។ ក្នុងសីលធម៌របស់ថៅហ្វាយនាយនេះ ព្រះសម្មាសម្ពុទ្ធបានសម្តែងថា ថៅហ្វាយនាយមានតួនាទី៥យ៉ាងគឺ ចាត់ការងារឱ្យសមគួរដល់កម្លាំងកម្មករ១ ឱ្យអាហារ និងថ្លៃឈ្នួលសមរម្យ១ ជួយព្យាបាលជំងឺនៅពេលឈឺថ្កាត់១ ចែករំលែករបស់ដែលមានរសជាតិប្លែក១ ឱ្យឈប់សម្រាកក្នុងសម័យដ៏គួរ១។ ទន្ទឹមនឹងនោះ កម្មករក៏ត្រូវមានសីលធម៌៥យ៉ាងចំពោះថៅហ្វាយនាយផងដែរ គឺ ត្រូវធ្វើការមុន១ ត្រូវឈប់ធ្វើការក្រោយ១ កាន់យកតែរបស់ដែលថៅហ្វាយនាយឱ្យ១ ធ្វើការដោយយកចិត្តទុកដាក់១ សរសើរគុណថៅហ្វាយនាយ១។ តាមរយៈព្រះពុទ្ធវចនៈទាំងនេះ គឺបង្ហាញថា ព្រះពុទ្ធសាសនាពិតជាចូលរួមចំណែកខ្លាំងណាស់ក្នុងការលើកកម្ពស់សីលធម៌ក្នុងវិជ្ជាជីវៈ។

### ៤-សីលធម៌ក្នុងសង្គម

ការរស់នៅក្នុងសង្គម មនុស្សយើងត្រូវមានទំនាក់ទំនងជាមួយអ្នកដទៃដោយចៀសមិនរួចឡើយ។ នេះមានន័យថា ការប្រស្រ័យទាក់ទងគ្នា គឺជារឿងសំខាន់ណាស់ ព្រោះថាជាការកំណត់សុខទុក្ខរបស់យើង និងសង្គមជាតិផងដែរ។ ហេតុនេះហើយ ការរស់នៅដោយមានសីលធម៌ក្នុងសង្គមគឺជាការចាំបាច់ណាស់។ "សីលធម៌ក្នុងសង្គម" សំដៅដល់ការយល់ដឹងថា មនុស្សយើងត្រូវរស់នៅដោយមានទំនាក់ទំនងល្អ ចេះសាមគ្គីគ្នា គិតប្រយោជន៍រួម មិនឈ្លានពានអ្នកដទៃ មិនរើសអើងវណ្ណៈ និងមិនប្រកាន់ពូជសាសន៍ជាដើម។ បើសង្គមពោរពេញដោយសីលធម៌ ច្បាស់ណាស់ថា សង្គមនឹងរីកចម្រើន គ្មានអសន្តិសុខ និងមានសេចក្តីថ្លៃថ្នូរទៀតផង។ ទាក់ទងនឹងការលើកកម្ពស់ឱ្យមានសីលធម៌នៅក្នុងសង្គមនេះ ព្រះពុទ្ធបានសម្តែងធម៌ឱ្យមនុស្សប្រតិបត្តិនូវសង្គហធម៌ ដែលជាធម៌នាំឱ្យមានសាមគ្គីភាព និងការមិនរើសអើងមើលងាយគ្នា។ សង្គហធម៌មាន៤ប្រការ គឺទានៈ១ បិយវាចា១ អត្ថចរិយា១ និងសមានត្តតា១។ ទានៈ គឺការចេះចែកទាន មានវត្ថុផ្សេងៗ ដែលជាការចែកនូវសេចក្តីសុខដល់អ្នកដទៃ។ ទន្ទឹមនឹងនោះ ការសម្តែងធម៌ និងការបង្រៀន ក៏ជាការធ្វើទានដែរ ហើយជាទានដ៏ប្រសើរទៀតផង។ បិយវាចា គឺសំដៅដល់ការនិយាយស្តីប្រកបដោយពាក្យសុភាពរាបសា ហើយជាសម្តីដែលនាំមកនូវប្រយោជន៍។ អត្ថចរិយា គឺការធ្វើនូវអំពើទាំងឡាយដែលនាំឱ្យកើត

ប្រយោជន៍ដល់ខ្លួន ដល់អ្នកដទៃ និងដល់សង្គមជាតិ។ សមានត្តតា មានន័យថាការរក្សាខ្លួនឱ្យស្មើ កុំឆ្មើងឆ្មៃ កុំក្រអឺតក្រទម កុំមានះ ពោលគឺត្រូវធ្វើជាមនុស្សដែលគេអាចរាប់អានបាន។ មនុស្សយើងមានគុណសម្បត្តិ និងសមត្ថភាពមិនដូចគ្នានោះទេ។ ដូច្នេះ ត្រូវចេះជួយគ្នាដោយធម៌ទាំងបួនប្រការនេះ។ បើក្នុងសង្គមមានធម៌ទាំងបួនប្រការនេះ សង្គមនោះនឹងពោរពេញដោយស្នាមញញឹម ប្រជាជនចេះសាមគ្គីគ្នា ហើយសង្គមនឹងរីកចម្រើនប្រកបដោយសេចក្ដីថ្លៃថ្នូរ។ ការរាប់អានគ្នានេះ ព្រះពុទ្ធក៏បង្ហាញឱ្យយើងឃើញពីមនុស្សគួររាប់អានផងដែរ។ មិត្តភក្តិ ឬមនុស្សដែលយើងគួររាប់អានហៅថា សុហទមិត្ត។ សុហទមិត្ត គឺមិត្តពិតប្រាកដ មិត្តល្អ ឬកល្យាណមិត្ត មាន៤យ៉ាង គឺ មិត្តមានឧបការៈចេះជួយថែរក្សាគ្នា១ មិត្តរួមសុខទុក្ខ មិនបោះបង់គ្នាក្នុងគ្រាមានអាសន្ន១ មិត្តណែនាំគ្នាឱ្យបានចម្រើន១ មិត្តមានចិត្តចង់ជួយគ្នា១។ ធម៌ទាំង៤ប្រការនេះ នឹងធ្វើឱ្យមនុស្សយើងក្លាយជាកល្យាណមិត្ត មិត្តដែលចេះការពារថែរក្សាគ្នា ចេះខ្វល់ខ្វាយពីមិត្តភក្តិ និងជាមិត្តដែលនាំឱ្យកើតនូវសេចក្ដីចម្រើន។ ទាក់ទងនឹងសីលធម៌នៃការរស់នៅក្នុងសង្គមនេះ ព្រះពុទ្ធក៏មានសម្ដែងផងដែរអំពីតួនាទីអ្នកកាន់សាសនា មានសមណព្រាហ្មណ៍ និងបរិស័ទជាដើម។ ព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់ថា បរិស័ទត្រូវទំនុកបម្រុងសមណព្រាហ្មណ៍ដោយធម៌៥ប្រការ គឺ ការគោរពដោយកាយកម្ម១ ការគោរពដោយវចីកម្ម១ ការគោរពដោយមនោកម្ម១ ការគោរពដោយបើកទ្វារឱ្យចេញចូលតាមពេលដ៏គួរ១ ការគោរពដោយការជួយសង្គ្រោះដោយអាហារជាដើម១។ ចំណែកសមណព្រាហ្មណ៍វិញ ត្រូវមានធម៌៦ប្រការចំពោះបរិស័ទគឺ ការពារមិនឱ្យធ្វើសេចក្ដីអាក្រក់១ ឱ្យតម្កល់ខ្លួននៅក្នុងសេចក្ដីល្អ១ អនុគ្រោះដោយទឹកចិត្តល្អ១ ឱ្យបានស្ដាប់ធម៌ដែលមិនធ្លាប់បានស្ដាប់១ បំភ្លឺធម៌ដែលធ្លាប់បានរៀនហើយ ឱ្យកាន់តែយល់ច្បាស់១ ប្រាប់ផ្លូវសម្រាប់ដើរទៅកាន់សេចក្ដីសុខចម្រើន១។ ការប្រតិបត្តិនូវតួនាទីទាំងនេះ មិនត្រឹមតែធ្វើឱ្យអ្នកកាន់ព្រះពុទ្ធសាសនាបានសុខនោះទេ គឺធ្វើឱ្យសង្គមមានសេចក្ដីចម្រើនទៀតផង។ ការធ្វើឱ្យប្រជាជន និងសង្គមបានសុខសន្តិភាពនេះ ក្នុងព្រះពុទ្ធសាសនាក៏មានសម្ដែងអំពីធម៌សម្រាប់អ្នកដឹកនាំផងដែរ។ ធម៌ដែលលើកស្ទួយឱ្យអ្នកដឹកនាំមានតម្លៃហៅថានាយកធម៌ មាន៦យ៉ាងគឺ ខមា សេចក្ដីអត់ធន់១ ជាគរិយៈ សេចក្ដីភ្ញាក់រលឹករឿយៗ១ ឧដ្ឋានៈ សេចក្ដីឧស្សាហ៍ខ្នះខ្នែង១ សំវិភាគៈ ការចែករំលែកឱ្យនូវវត្ថុផ្សេងៗ១ ទយា សេចក្ដីអាណិតអាសូរត្រាប្រណីគេ១ ឥក្ខណា ការរំពៃមើលខុសត្រូវ១។ ទាក់ទងការដឹកនាំប្រទេសនេះ ព្រះពុទ្ធក៏បានបង្ហាញនូវសីលធម៌របស់អ្នកដឹកនាំផងដែរ ហៅថាទសពិធរាជធម៌។ ទសពិធរាជធម៌ គឺជាធម៌សម្រាប់ព្រះរាជា ពោលគឺជាធម៌សម្រាប់អ្នកដឹកនាំគ្រប់ជាន់ថ្នាក់។ ទសពិធរាជធម៌មាន១០យ៉ាង គឺ ទានៈ ការឱ្យនូវទ្រព្យចំពោះអ្នកដទៃ១ សីលៈ ការរក្សាមារយាទរបស់ខ្លួនឱ្យមានរបៀបរៀបរយ និងឱ្យមានសេចក្ដីថ្លៃថ្នូរ១ បរិច្ចាគៈ ការចំណាយព្រះរាជទ្រព្យទំនុកបម្រុងប្រទេសជាតិ ឬលះបង់ទ្រព្យសម្បត្តិ និងសេចក្ដីសុខរបស់ខ្លួនដើម្បីប្រយោជន៍រួម មិនចំពោះបុគ្គលឬក្រុមណាមួយឡើយ១ អាជ្ជវៈ ការធ្វើខ្លួនឱ្យមានអធ្យាស្រ័យទៀងត្រង់១ មទ្ទវៈ ការធ្វើខ្លួនឱ្យមានអធ្យាស្រ័យទន់ភ្លន់សុភាពរាបសា១ តបៈ ការព្យាយាមកម្ចាត់បង់នូវសេចក្ដីអាក្រក់របស់ខ្លួនឱ្យបាន១ អក្កោធនៈ មិនមានសេចក្ដីក្រេវក្រោធ១ អវិហឹសា មិនបៀតបៀនមនុស្សឥតកំហុស១ ខន្តិ មានសេចក្ដីអត់ធន់១ អវិរោធនៈ មិនមានការប្រព្រឹត្តបំពានលើច្បាប់១។ អ្នកដឹកនាំគ្រប់ជាន់ថ្នាក់ដែលបានដើរតាមសីលធម៌ទាំង១០របស់អ្នកដឹកនាំនេះ នឹងធ្វើឱ្យប្រជារាស្ត្រពេញចិត្ត ហើយធ្វើឱ្យសង្គមជាតិមានសេចក្ដីសុខ មានសន្តិភាព មានការរីកចម្រើន ព្រមទាំងមានទំនាក់ទំនងល្អជាសកលទៀតផង។ នេះជាសក្ខីភាពបង្ហាញយ៉ាងច្បាស់ថា ព្រះពុទ្ធសាសនាពិតជាបានចូលរួមយ៉ាងច្រើនក្នុងការលើកម្ពស់សីលធម៌សង្គម។

### ៥-សីលធម៌សកល

សីលធម៌សកល គឺជាសីលធម៌រួមរបស់មនុស្សជាតិ។ នៅពេលដែលយើងដឹងថា ការរស់នៅក្នុងសកលលោកនេះ យើងត្រូវមានសីលធម៌ក្នុងការរាប់អាន ឬធ្វើទំនាក់ទំនងជាមួយមនុស្សដែលជាជនជាតិដទៃ អ្នកមានសញ្ជាតិ ឬអ្នកប្រើភាសាខុសពីយើង ការមិនរើសអើង និងការមិនមើលងាយគេជាដើម នោះឈ្មោះថាយើងមានសីលធម៌សកល។ ការរើសអើងជាតិសាសន៍ ពណ៌សម្បុរ គឺជារឿងអសីលធម៌មួយដែលធ្វើឱ្យទំនាក់ទំនងរវាងជាតិនិងជាតិឈានទៅរកការបែកបាក់ ឬបង្កទៅជាមានសង្គ្រាមទៀតផង។ ក្នុងព្រះពុទ្ធសាសនាបានបង្រៀនអ្នកដឹកនាំ និងមនុស្សទូទៅឱ្យមានព្រហ្មវិហារធម៌ដែលជាធម៌ដ៏ប្រសើរ នាំឱ្យមានសាមគ្គីភាពប្រកបដោយសុខដុមរមនា។ ព្រហ្មវិហារធម៌ មាន៤យ៉ាង គឺមេត្តា១ ករុណា១ មុទិតា១ និងឧបេក្ខា១។ មេត្តា គឺការមានចិត្តស្រឡាញ់រាប់អានញាតិមិត្ត និងសាធារណជនដោយគ្មានការរើសអើង និងប្រកបដោយសន្តានចិត្តភក្តីទូលាយ ដូចជាមាតាបិតាចង់ឱ្យកូនបានសុខ បានចម្រើន ចៀសផុតពីទុក្ខវេទនា ពៀរវេរា និងគ្រោះមហន្តរាយគ្រប់ប្រការ។ ករុណា គឺការមានចិត្តអាណិតអាសូរ ដោយគ្មានប្រណែនឈ្នានីស យកត្រូវតែខ្លួនឯង ទិតៀនរិះគន់កំហុសអ្នកដទៃឡើយ។ ការអាណិតអាសូរនេះ គឺមានចំពោះមនុស្សទូទៅទាំងអស់នៅក្នុងសង្គមដែលបានទទួលរងទុក្ខលំបាកផ្សេងៗទាំងផ្លូវចិត្ត ទាំងផ្លូវកាយ ដោយចង់ឱ្យពួកគេរួចពីទុក្ខលំបាក និងរស់នៅបានសុខស្រួលដូចខ្លួនដែរ។ មុទិតា គឺមានចិត្តទន់ភ្លន់ មានចិត្តរីករាយអបអរសាទរចំពោះសេចក្តីសុខចម្រើនរបស់អ្នកដទៃមិនរើសមុខ និងចង់ឱ្យគេស្ថិតនៅក្នុងសេចក្តីសុខ សុវត្ថិភាពជានិច្ច ដោយគ្មានការប្រណែននិន្ទាឈ្នានីស។ ឧបេក្ខា គឺការប្រកាន់ចិត្តជាកណ្តាល មិនលម្អៀងទៅខាងណា និងមានចិត្តជាអព្យាក្រឹត។ អ្នកមានឧបេក្ខា មិនមានចិត្តត្រេកអរហួសហេតុ និងមិនខឹងសម្បាចំពោះអ្នកណាទាំងអស់។ បំណងសំខាន់របស់អ្នកមានឧបេក្ខា គឺចង់ឱ្យពួកគេរស់នៅតាមលទ្ធភាព សមត្ថភាព និងសេរីភាពរបស់គេ ហើយមិនមានចិត្តលោភលន់ ឬព្រួយកង្វល់ចំពោះអ្នកជិតខាងដែលមានទ្រព្យសម្បត្តិជាងខ្លួន។ ព្រហ្មវិហារធម៌ទាំង៤នេះ ជាប្រភពនៃសន្តិភាព និងវឌ្ឍនភាពនៃសង្គម និងពិភពលោក ដូចមានពុទ្ធគាថាដែលព្រះសម្មាសម្ពុទ្ធបានសម្តែងថា នត្ថិ សន្តិ បរំ សុខំ មានន័យថា គ្មានសេចក្តីសុខដទៃក្រៅអំពីសេចក្តីស្ងប់ឡើយ។ ទាំងនេះ បញ្ជាក់បានថា ព្រះពុទ្ធសាសនាពិតជាបានលើកកម្ពស់សីលធម៌សកលយ៉ាងពិតប្រាកដ។

និយាយជារួមមក ការអប់រំសីលធម៌របស់ព្រះពុទ្ធសាសនា គឺព្រះពុទ្ធទ្រង់បានឱ្យប្រតិបត្តិតាមអដ្ឋង្គិកមគ្គ ដើម្បីឱ្យរួចចាកទុក្ខ ហើយបាននូវសេចក្តីសុខ រហូតដល់បរមសុខ។ អដ្ឋង្គិកមគ្គ មានន័យថាផ្លូវត្រូវ ផ្លូវដ៏ប្រពៃទាំង៨ គឺ សម្មាទិដ្ឋិ ការយល់ឃើញត្រូវ១ សម្មាសង្កប្បៈ ការត្រិះរិះត្រូវ១ សម្មាវាចា ការមានវាចាត្រឹមត្រូវ១ សម្មាកម្មន្តៈ ការធ្វើការងារត្រូវ១ សម្មាអាជីវៈ ការចិញ្ចឹមជីវិតត្រូវ១ សម្មាវាយាមៈ ការព្យាយាមត្រូវ១ សម្មាសតិ ការមានស្មារតីត្រូវ ឬការរឭកត្រូវ១ សម្មាសមាធិ ការតាំងចិត្តត្រូវ ឬការមានសមាធិត្រូវ១។

### ខ-ចរិយាធម៌

ដូចបានរំឭកម្តងហើយថា ចរិយាធម៌ សំដៅដល់ការប្រព្រឹត្តនូវអំពើល្អដោយកាយ វាចា និងចិត្ត។ ចរិយាធម៌នេះ ខុសពីសីលធម៌ត្រង់ថា មនុស្សយកទ្រឹស្តីសីលធម៌មកអនុវត្ត មកប្រតិបត្តិតាម ហៅថាចរិយាធម៌។ នេះមានន័យថា សីលធម៌សំដៅដល់ពាក្យប្រៀនប្រដៅរបស់ព្រះសម្មាសម្ពុទ្ធ ដែលទ្រង់បង្ហាញផ្លូវឱ្យយើងឃើញថា ផ្លូវណាល្អ ផ្លូវណាអាក្រក់។ នៅពេលដែលយើងយកឱវាទរបស់ព្រះអង្គមកប្រតិបត្តិដើម្បីឱ្យក្លាយជាមនុស្សល្អ នោះយើងនឹងបានឈ្មោះថា ជាអ្នកមានចរិយាធម៌ល្អ។

ព្រះពុទ្ធសាសនា ពិតជាមានតួនាទីយ៉ាងសំខាន់បំផុតក្នុងការលើកកម្ពស់ឱ្យមានចរិយាធម៌។ តាមរយៈការយកនូវព្រះពុទ្ធឱវាទមកសម្ដែង មកបង្រៀនដល់ប្រជាជន តាមមធ្យោបាយផ្សេងៗនោះ ធ្វើឱ្យពុទ្ធបរិស័ទបានចេះដឹង និងប្រតិបត្តិតាមសីលធម៌របស់ព្រះពុទ្ធសាសនា។ លទ្ធផលដែលកើតចេញពីការប្រតិបត្តិតាមសីលធម៌ទាំងនោះ ធ្វើឱ្យមនុស្សជាច្រើនបានប្រព្រឹត្តល្អ ពោលគឺក្លាយជាមនុស្សមានចរិយាធម៌ដ៏ប្រពៃ។ ចរិយាធម៌ដែលមនុស្សទទួលបានពីការដើរតាមមាគ៌ារបស់ព្រះពុទ្ធសាសនាមានច្រើនប្រការណាស់។

**១- ចរិយាធម៌សម្រាប់ខ្លួន**

មនុស្សដែលមានចរិយាធម៌ គឺសំដៅដល់មនុស្សដែលបានធ្វើនូវអំពើល្អ។ អ្នកធ្វើនូវអំពើល្អទាំងនោះ គឺល្អទាំងក្នុងទីស្ងាត់កំបាំង និងល្អទាំងនៅទីចំពោះមុខអ្នកដទៃ។ ជាការពិតណាស់ អ្នកដែលបានប្រតិបត្តិតាមឃរាវាសធម៌ និងកល្យាណធម៌ជាដើម ដែលជាពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធ នឹងធ្វើឱ្យគេក្លាយជាមនុស្សល្អ ឬហៅថាជាអ្នកដែលមានចរិយាធម៌ល្អ។ អ្នកទាំងនោះ រមែងធ្វើអំពើល្អ ដូចជាការចិញ្ចឹមជីវិតដោយត្រឹមត្រូវ មានសាមគ្គីភាព មានសេចក្ដីអត់ធន់ ចេះធ្វើបុណ្យទាន ជួយកសាងវត្តអារាម អណ្ដូងទឹក មន្ទីរពេទ្យ សាលារៀនជាដើម។ ម្យ៉ាងវិញទៀត អ្នកដែលមានសេចក្ដីព្យាយាម មិនខ្ជិលច្រអូស ប្រឹងប្រែងធ្វើការងារ លះបង់នូវគ្រឿងអបាយមុខផ្សេងៗមានល្បែងស្រី ស្រា ល្បែងភ្នាល់ជាដើម ក៏ឈ្មោះថាជាអ្នកមានចរិយាធម៌ល្អដែរ។ នៅពេលមនុស្សមានចរិយាធម៌ល្អ នឹងធ្វើឱ្យពួកគេមានសេចក្ដីសុខ គ្រួសារមានសុភមង្គល ធ្វើការងារអ្វីក៏បានសម្រេចជោគជ័យ ព្រមទាំងនាំសេចក្ដីចម្រើន និងភាពសុខសាន្តត្រាណដល់សង្គមជាតិផងដែរ។

**២- ចរិយាធម៌សម្រាប់គ្រួសារ**

អ្នកប្រព្រឹត្តល្អក្នុងគ្រួសារ គឺឈ្មោះថាជាអ្នកមានចរិយាធម៌ល្អក្នុងគ្រួសារ។ កូនដែលមានចរិយាធម៌ល្អរមែងធ្វើល្អតបគុណមាតាបិតា ដូចជាការជូនលុយកាក់ ឬធ្វើផ្ទះសំបែងជូនអ្នកមានគុណ និងធ្វើសេចក្ដីល្អផ្សេងៗទៀតចំពោះមាតាបិតា។ កូនទាំងនោះ នឹងក្លាយជាកូនល្អ កូនកតញ្ញូក្នុងគ្រួសារ និងជាប្រជាជនល្អក្នុងសង្គម។ ចំណែកម្ដាយឪពុកដែលបានបំពេញតួនាទីត្រឹមត្រូវតាមធម៌ ដូចជាការប្រាប់ឱ្យកូនស្គាល់ល្អ ស្គាល់អាក្រក់ និងបញ្ជូនកូនឱ្យទៅរៀនសូត្រជាដើម អ្នកទាំងនោះនឹងបានឈ្មោះថា ជាមាតាបិតាដែលមានព្រហ្មវិហារធម៌ និងចរិយាធម៌ល្អចំពោះកូនៗ។ រីឯប្ដីប្រពន្ធវិញ បើបានបំពេញតាមតួនាទីរបស់ខ្លួន មានការគោរពគ្នា មានភក្ដីភាព និងការផ្ដល់តម្លៃឱ្យគ្នាជាដើម គេនឹងបានឈ្មោះថា ជាប្ដីល្អ ឬប្រពន្ធល្អ ពោលគឺជាប្ដីប្រពន្ធដែលមានចរិយាធម៌ល្អ។ នៅក្នុងគ្រួសារដែលពោរពេញដោយការប្រព្រឹត្តល្អស្របតាមពុទ្ធឱវាទនោះ នឹងធ្វើឱ្យអ្នកផងទាំងពួងពោលសរសើរ ស្រឡាញ់រាប់អាន ព្រមទាំងធ្វើឱ្យគ្រួសារមានទ្រព្យសម្បត្តិស្ដុកស្ដម្ភ មានសេចក្ដីសុខ សុភមង្គល គ្មានអំពើហិង្សា និងរស់នៅយ៉ាងមានកិត្តិយសប្រពៃថ្លៃថ្លា។

**៣- ចរិយាធម៌សម្រាប់វិជ្ជាជីវៈ**

មនុស្សដែលរកស៊ីត្រឹមត្រូវ មិនខុសសីលធម៌ មិនខុសច្បាប់ប្រទេស នោះឈ្មោះថាជាអ្នករកស៊ីដែលមានចរិយាធម៌ល្អ។ អ្នករកស៊ីទាំងនោះ មិនត្រឹមតែរកស៊ីដោយសម្មាអាជីវៈ ពោលគឺការរកស៊ីប្រកបដោយធម៌ និងស្របតាមច្បាប់ប្រទេសនោះទេ ត្រូវតែជាអ្នករកស៊ីដែលមានភាពស្មោះត្រង់ និងមានការសន្ដោសប្រណីផងដែរ។ អ្នកដែលលះបង់នូវមិច្ឆាជីវៈ ហើយរកស៊ីដោយសម្មាអាជីវៈតាមពុទ្ធឱវាទទាំងនោះ រមែងទទួលបាននូវការគោរពស្រឡាញ់ និងការទុកចិត្តពីអតិថិជន ធ្វើឱ្យមុខជំនួញរបស់ពួកគេកាន់តែជោគជ័យ។ សម្រាប់អ្នកមានវិជ្ជាជីវៈជាគ្រូបង្រៀនដែលបានបំពេញតាមតួនាទី គឺបង្រៀនសិស្សដោយល្អ បង្រៀនដោយយកចិត្ត

ទុកដាក់ និងមើលថែការពារសិស្សជាដើម ឈ្មោះថាជាគ្រូដែលមានចរិយាធម៌ក្នុងវិជ្ជាជីវៈ។ លោកគ្រូអ្នកគ្រូទាំងនោះនឹងធ្វើឱ្យសិស្សក្លាយជាធនធានមនុស្ស ហើយលោកគ្រូអ្នកគ្រូទាំងនោះក៏នឹងមានកេរ្តិ៍ឈ្មោះល្អផងដែរ។ ចំណែកសិស្សានុសិស្សដែលបានគោរពតួនាទីរបស់ខ្លួនដូចជាគោរពគ្រូ និងប្រឹងប្រែងរៀនជាដើម ពួកគេនឹងក្លាយជាសិស្សល្អ មានចំណេះដឹង ពោលគឺអាចបង្កើតប្រយោជន៍ដល់ខ្លួនឯង ដល់គ្រូបង្រៀន និងដល់សង្គមទៀតផង។ រីឯថៅហ្វាយនាយ ដែលបានបំពេញតួនាទីបានល្អ មានការគោរពសិទ្ធិកម្មករ និងគោរពតាមច្បាប់ការងារ ឈ្មោះថាជាថៅហ្វាយនាយដែលមានចរិយាធម៌ល្អ។ មនុស្សប្រភេទនេះ នឹងធ្វើឱ្យកម្មករ ឬអ្នកនៅក្រោមឱវាទ មានសេចក្តីពេញចិត្ត ដែលជាហេតុធ្វើឱ្យបុគ្គលិកទាំងនោះប្រឹងប្រែងធ្វើការដោយភាពស្មោះស្ម័គ្រទៀតផង។ ចំណែកកម្មករ ឬបុគ្គលិកដែលធ្វើការឱ្យគេវិញ បើយកចិត្តទុកដាក់ និងស្មោះត្រង់ចំពោះការងារ មុខជាធ្វើឱ្យថៅហ្វាយនាយស្រឡាញ់ពេញចិត្ត។ កម្មករ ឬបុគ្គលិកដែលមានចរិយាធម៌ល្អនោះនឹងទទួលបានជោគជ័យក្នុងការងារ រស់នៅមានសេចក្តីសុខ និងមានអនាគតល្អ។

### ៤- ចរិយាធម៌សម្រាប់សង្គមជាតិ

ការប្រព្រឹត្តរបស់មនុស្សគ្រប់រូប គឺជារឿងសំខាន់ណាស់សម្រាប់សង្គម ព្រោះថា មនុស្សគឺជាកោសិការបស់សង្គម។ អ្នកធ្វើល្អមិនត្រឹមតែជួយខ្លួនឯងឱ្យមានសេចក្តីសុខនោះទេ ថែមទាំងមានឥទ្ធិពលដល់ការធ្វើឱ្យប្រទេសជាតិមានការរីកចម្រើនទៀតផង។ អំពើល្អដែលនាំឱ្យសង្គមជាតិមានវឌ្ឍនភាពនោះឯង គឺជាចរិយាធម៌ល្អសម្រាប់សង្គមជាតិ។ ជាក់ស្តែង មនុស្សដែលបានប្រតិបត្តិនូវសង្គហធម៌តាមពុទ្ធឱវាទ មានការធ្វើទាន ការធ្វើនូវអំពើជាប្រយោជន៍ផ្សេងៗ និងការតម្កល់ខ្លួនដោយប្រពៃ មិនឆ្មើងឆ្មៃជាដើមនោះ នឹងធ្វើឱ្យពួកគេរស់នៅពោរពេញដោយសេចក្តីល្អ ប្រកបដោយភាពថ្លៃថ្នូរ។ ទន្ទឹមនឹងនោះ សកម្មភាពរបស់ពួកគេ នឹងក្លាយជាគំរូដល់អ្នកដទៃផងដែរ។ ម្យ៉ាងវិញទៀត ការរាប់អានមិត្តភក្តិដែលចេះជួយគ្នា និងមិត្តភក្តិដែលនាំគ្នាធ្វើតែអំពើល្អស្របតាមមេរៀនរបស់ព្រះពុទ្ធសាសនានោះ គឺជាចរិយាធម៌ដ៏ល្អដែលនាំឱ្យមានសេចក្តីចម្រើនដល់មនុស្ស និងសង្គមជាតិ។ ការប្រព្រឹត្តនូវចរិយាធម៌នេះ មិនមែនមានតួនាទីតែប្រជារាស្ត្រនោះទេ តែក៏ជាតួនាទីរបស់អ្នកដឹកនាំផងដែរ។ អ្នកដឹកនាំដែលបានអនុវត្តតាមទសពិធរាជធម៌ ឈ្មោះថាជាអ្នកដឹកនាំដែលមានចរិយាធម៌ល្អ។ អ្នកដឹកនាំប្រភេទនេះ នឹងធ្វើឱ្យប្រជារាស្ត្រ ឬអ្នកគាំទ្រពេញចិត្ត ព្រោះបានធ្វើឱ្យប្រជាជនមានសេចក្តីសុខ សេចក្តីចម្រើន រស់នៅក្នុងសុភមង្គល និងបានធ្វើឱ្យសង្គមជាតិមានសុខសន្តិភាព។

### ៥- ចរិយាធម៌សម្រាប់អន្តរជាតិ

ចរិយាធម៌សម្រាប់អន្តរជាតិ សំដៅដល់ការប្រព្រឹត្តល្អរបស់ប្រជាជន និងថ្នាក់ដឹកនាំប្រទេស ហើយផ្សាយនូវសេចក្តីល្អនោះដល់ពិភពលោក។ នៅពេលប្រជារាស្ត្រ និងថ្នាក់ដឹកនាំ បានប្រតិបត្តិនូវព្រហ្មវិហារធម៌មានមេត្តាជាដើមនោះ នឹងធ្វើឱ្យប្រទេសជាតិមានកេរ្តិ៍ឈ្មោះល្អ ព្រោះថា គ្មានការរើសអើងនូវវប្បធម៌ ពណ៌សម្បុរ ភាសា និងពូជសាសន៍ឡើយ។ បន្ថែមពីលើនេះ ការប្រតិបត្តិនូវសង្គហធម៌ គឺការជួយគ្នានោះ ក៏ធ្វើឱ្យមានការសាមគ្គីគ្នា ព្រមទាំងជាតិមានសុខសន្តិភាព និងមានឈ្មោះល្បីរន្ទឺផងដែរ ព្រោះថា គ្មានជនណាមួយចង់ទៅរករឿងចំពោះអ្នកដែលធ្លាប់មានគុណមកលើខ្លួននោះឡើយ ហើយថែមទាំងនឹកគុណដល់គេវិញទៀតផង។ ជាក់ស្តែង ការអនុញ្ញាតឱ្យនាវាទេសចរណ៍វេស្ទឺដាមចូលចតនៅកំពង់ផែប្រទេសកម្ពុជាកាលពីឆ្នាំ ២០២០ គឺជាការបង្ហាញនូវការជួយសង្គ្រោះប្រកដោយមេត្តារបស់អ្នកដឹកនាំខ្មែរ។ ក្នុងកំឡុងពេលនោះ មានអ្នកទេសចរណ៍ជាង២,២០០នាក់កំពុងជួបនូវទុក្ខធំ ដោយសារពិភពលោកកំពុងជួបប្រទះនូវជំងឺកូវីដ១៩។

នាវាវេស្ទឺដាមរបស់អាមេរិកនោះ ត្រូវបានប្រទេសចំនួន៥បដិសេធមិនឱ្យចូលចត ព្រោះខ្លាចឆ្លងជំងឺកូវីដ១៩នោះឯង។ ទន្ទឹមនឹងបញ្ហាខ្វះស្បៀងអាហារ បញ្ហាខ្វះប្រេង និងបញ្ហាគេមិនឱ្យចូលចត អ្នកទាំងអស់នោះត្រូវបានជួយសង្គ្រោះដោយប្រទេសកម្ពុជា ដែលអនុញ្ញាតឱ្យចូលចតលើទឹកដីខ្មែរដោយសម្ដេច ហ៊ុន សែន នាយករដ្ឋមន្ត្រី។ ដោយបេះដូងមនុស្សធម៌នេះ បានធ្វើឱ្យប្រជាជនខ្មែរ និងប្រទេសខ្មែរមានកិត្តិយសលើឆាកអន្តរជាតិ ថាជាប្រទេសតូច តែមានបេះដូងធំ។ ដោយសារចរិយាធម៌ដ៏ល្អនេះហើយ ទើបនាវាវេស្ទឺដាម និងភ្ញៀវទេសចរណ៍ជាង២,០០០នាក់ បានត្រឡប់មកលេងប្រទេសកម្ពុជាម្ដងទៀតនៅចុងឆ្នាំ២០២៣។ ការវិលមកលេងប្រទេសកម្ពុជាជាថ្មីនេះ គឺជាការតបគុណដែលកម្ពុជាបានជួយសង្គ្រោះពួកគេនោះឯង។ នេះបញ្ជាក់បានថា ពេលប្រជាជន និងថ្នាក់ដឹកនាំមានចរិយាធម៌ល្អនោះ នឹងធ្វើឱ្យប្រជាជនមានភាពសុខសាន្ត ប្រទេសជាតិមានសន្តិភាព ព្រមទាំងបានបង្ហាញនូវកេរ្តិ៍ដ៏ប្រពៃក្នុងឆាកអន្តរជាតិទៀតផង។

### ៤- សរុបសេចក្ដី

សរុបសេចក្ដីមក ព្រះពុទ្ធសាសនាបានចូលរួមយ៉ាងច្រើនក្នុងការលើកកម្ពស់សីលធម៌ និងចរិយាធម៌។ សីលធម៌ និងចរិយាធម៌ទាំងនោះ គឺបានជួយឱ្យមនុស្សយល់ដឹង និងប្រព្រឹត្តល្អដោយកាយ វាចា និងចិត្ត។ ព្រះពុទ្ធវចនៈ ដែលជាពាក្យប្រៀនប្រដៅរបស់ព្រះសម្មាសម្ពុទ្ធនោះ គឺត្រូវបានបង្រៀនមនុស្សគ្រប់ស្រទាប់វណ្ណៈ ទាំងប្រជារាស្ត្រ និងអ្នកដឹកនាំប្រទេស ឱ្យមានសីលធម៌ល្អ ទាំងសីលធម៌ផ្ទាល់ខ្លួន សីលធម៌ក្នុងគ្រួសារ សីលធម៌ក្នុងវិជ្ជាជីវៈ សីលធម៌ក្នុងសង្គម និងសីលធម៌សកល។ ការប្រតិបត្តិតាមសីលធម៌របស់ព្រះពុទ្ធសាសនានេះ បានធ្វើឱ្យមនុស្សមានចរិយាធម៌ គឺការប្រព្រឹត្តល្អ ដូចជាចេះគោរពមាតាបិតា គោរពរាប់អានមនុស្សក្នុងលោក ព្រមទាំងធ្វើការងារដែលមានប្រយោជន៍ និងការដឹកនាំល្អ ធ្វើឱ្យប្រជាជន និងសង្គមជាតិមានសុខសន្តិភាព។

## III.សេចក្ដីបញ្ចប់

ឆ្លងតាមការបកស្រាយមក យើងឃើញថា ប្រធានបទដែលត្រូវបានលើកឡើងក្នុងឱកាសទិវាជាតិអំណាន លើកទី៩នេះ ពិតជាមានអត្ថន័យជ្រាលជ្រៅណាស់ ដោយបានបើកបង្ហាញឱ្យឃើញអំពីតួនាទី និងតម្លៃនៃព្រះពុទ្ធសាសនាក្នុងការចូលរួមលើកកម្ពស់ការអប់រំសីលធម៌ និងចរិយាធម៌ដែលមានតម្លៃយ៉ាងខ្លាំងសម្រាប់ប្រជាជាតិខ្មែរ។ ដូច្នេះ ក្នុងនាមយើងជាពុទ្ធសាសនិក និងជាប្រជាជនខ្មែរត្រូវខិតខំសិក្សាឈ្វេងយល់ឱ្យបានច្រើននូវព្រះពុទ្ធដីកា ដើម្បីឱ្យមានចំណេះដឹង និងការអប់រំតាមរយៈព្រះពុទ្ធសាសនា។ ការសិក្សារៀនសូត្រនូវពុទ្ធឱវាទនោះ នឹងធ្វើឱ្យយើងអាចអប់រំខ្លួនឯងឱ្យក្លាយជាមនុស្សល្អ ពោលគឺជាមនុស្សដែលមានសីលធម៌ និងចរិយាធម៌ល្អ។ ការអប់រំនេះ មិនមែនដើម្បីតែធ្វើឱ្យខ្លួនយើងក្លាយជាកូនល្អ និងសិស្សល្អនោះទេ គឺដើម្បីប្រជាជនខ្មែរ និងប្រទេសកម្ពុជាទាំងមូល ព្រោះថា យើងអាចធ្វើជាគំរូនៃប្រជាពលរដ្ឋល្អក្នុងការផ្សព្វផ្សាយនូវទង្វើល្អទៅកាន់អ្នកដទៃក្នុងសង្គម។ នៅពេលដែលយើងជាមនុស្សដែលមានសីលធម៌ និងចរិយាធម៌ល្អ ច្បាស់ណាស់ថា នឹងធ្វើឱ្យខ្លួនយើងមានតម្លៃ មានគេស្រឡាញ់ចូលចិត្តច្រើន មានអនាគតល្អ គ្រួសារមានសេចក្ដីសុខ សុភមង្គល ហើយយើងក៏ឈ្មោះថាបានចូលរួមអភិវឌ្ឍប្រទេសជាតិឱ្យមានការរីកចម្រើនប្រកបដោយសេចក្ដីថ្លៃថ្នូរផងដែរ។

## ឯកសារពិគ្រោះ


- សុង ស៊ីវ, ព្រះពុទ្ធសាសនា និងវិទ្យាសាស្ត្រ
- ព្រះគ្រូសង្ឃសុមេធ ធន់ វ៉ាន់, ប្រស្នាពុទ្ធសាសនា
- ពុទ្ធសាសនបណ្ឌិត្យកម្ពុជរដ្ឋ, ពុទ្ធសាសនា២៥០០
- ក្រុមបណ្ឌិតពុទ្ធសាសនា, ធម្មសមុហកថា
- ឈុន គឹមអៀត, ព្រះពុទ្ធដីកា
- ភិក្ខុ ងិន ភេន ឥន្ទប្បញ្ញោ, ពុទ្ធសាសនា និង សង្គម
- ឥន្ទប្បញ្ញោភិក្ខុ ហ. មណីចិន្តា, ព្រះបាទធម្មិក
- ក្រសួងអប់រំ យុវជន និងកីឡា,សៀវភៅសិក្សាសង្គម ថ្នាក់ទី១០
- ក្រសួងអប់រំ យុវជន និងកីឡា,សៀវភៅសីលធម៌-ពលរដ្ឋវិជ្ជា ថ្នាក់ទី១១
- ក្រសួងអប់រំ យុវជន និងកីឡា,សៀវភៅសីលធម៌-ពលរដ្ឋវិជ្ជា ថ្នាក់ទី១២
- ភិក្ខុធម្មបាល ខៀវ ជុំ, ជីវិតសន្តិភាព
- ស៊ិន សុវណ្ណនិ, ឯកសារស្រាវជ្រាវក្រុមជុំនុំប្រែគម្ពីរព្រះត្រៃបិដកនៃប្រទេសកម្ពុជា
- ម៉ិញ ន៉ាគ្រី, សាសនាគឺអ្វី?
- លោកស្រីបណ្ឌិត ជា វណ្ណី, ព្រះពុទ្ធសាសនា និងការអភិវឌ្ឍសង្គមកម្ពុជា, បង្ហោះនៅគេហទំព័រ https://ihss.rac.gov.kh (រាជបណ្ឌិតសភាកម្ពុជា)
- https://www.dictionary.com